*បកប្រែក្រៅផ្លូវការ*

# ស្តង់ដា

# ទីក្រុងទេសចរណ៍ស្អាតអាស៊ាន

រៀបចំដោយៈ ក្រសួងទេសចរណ៍កម្ពុជា

# មាតិកា


**១. បុព្វកថា------------------------------------------------------------------------------------------- ៤**

**២. សេចក្តីផ្តើម------------------------------------------------------------------------------------------ ៥**

**៣. វិសាសភាព ------------------------------------------------------------------------------------------ ៦**

**៤. ពាក្យគន្លឹះ និងនិយមន័យ------------------------------------------------------------------------------ ៦**

៤.១ .ភាពស្អាត...................................................................................................... ៦

៤.២ .តំបន់បង់ប្រាក់សម្រាប់ការកកស្ទះ.......................................................................... ៦

៤.៣ .យាន្តយន្តដែលគិតគូពីបរិស្ថាន............................................................................. ៦

៤.៤ .បទដ្ឋានគតិយុត្តស្តីពីបរិស្ថាន.............................................................................. ៦

៤.៥ .តំបន់បៃតង...................................................................................................... ៦

៤.៦. មណ្ឌលសុខភាព................................................................................................ ៦

៤.៧. សកម្មភាពខុសច្បាប់ ......................................................................................... ៧

៤.៨. បទដ្ឋាន............................................................................................................៧

៤.៩ .កម្មវិធីដំណើរទស្សនាកំសាន្តរបស់ភ្ញៀវទេសចរដោយមានប្លង់ច្បាស់លាស់ ........................ ៧

៤.១០. ការបំពុល (ទឹក ខ្យល់ និងដោយសម្លេង) ................................................................. ៧

៤.១១. តំបន់សាធារណៈ................................................................................................ ៧

៤.១២ .ការបញ្ជ្រាបការយល់ដឹង ..................................................................................... ៧

៤.១៣. ការកែច្នៃ.......................................................................................................... ៧

៤.១៤. ថាមពលកកើតឡើងវិញ ...................................................................................... ៨

៤.១៥. ការគ្រប់គ្រងហានិភ័យ ........................................................................................ ៨

៤.១៦. ទីក្រុងទេសចរណ៍................................................................................................ ៨

៤.១៧. ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍................................................................................ ៨

៤.១៨. នគរបាលទេសចរណ៍ .......................................................................................... ៨

៤.១៩. ផែនការទីក្រុង ................................................................................................... ៨

៤.២០. ការគ្រប់គ្រងសំណល់ ........................................................................................... ៨

**៥ .ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន -សូចនាករ ----------------------------------------------- ៨**

**៥.១.សូចនាករស្តីពីការគ្រប់គ្រងបរិស្ថាន**................................................................................ ៨

៥.១.១. ផែនការទីក្រុង.................................................................................................. ៩

៥.១.២. បទបញ្ញត្តិស្តីពីបរិស្ថាន......................................................................................... ៩

៥.១.៣. ការបំពុល (ទឹក ខ្យល់ និងសំលេង) ..................... ៩
៥.១.៤. មធ្យោបាយធ្វើដំណើរដែលគិតគូពីបរិស្ថាន ..................... ៩
៥.១.៥. ការប្រើប្រាស់ថាមពលប្រកបដោយនិរន្តរភាព ..................... ១០
**៥.២. សូចនាករស្តីពីភាពស្អាត ..................... ១០**
៥.២.១. ភាពស្អាតនៅតាមទីកន្លែងសាធារណៈ ..................... ១០
៥.២.២. ភាពស្អាតនៅតាមបង្គន់សាធារណៈ ..................... ១០
៥.២.៣.ភាពស្អាតនៅតាមរមណីយដ្ឋានទេសចរណ៍ (សារមន្ទីរ ប្រាសាទ សួនឧទ្យាន ឆ្នេរសមុទ្រជាដើម)... ..................... ១០
៥.២.៤. ភាពស្អាតតាមផ្លូវសំខាន់ៗ ..................... ១១
**៥.៣. សូចនាករស្តីពីការគ្រប់គ្រងសំណល់ ..................... ១១**
៥.៣.១. ការប្រមូលសំណល់រាវ ..................... ១១
៥.៣.២. ការប្រមូលសំណល់រឹង ..................... ១១
៥.៣.៣. ការស្តុក និងប្រព្រឹត្តកម្មសំណល់រាវ ..................... ១១
៥.៣.៤. ការស្តុក និងប្រព្រឹត្តកម្មសំណល់រឹង ..................... ១២
៥.៣.៥. ការកែច្នៃឡើងវិញ ..................... ១២
**៥.៤. សូចនាករស្តីពីការបញ្ជ្រាបការយល់អំពីកិច្ចការពារបរិស្ថាន និងភាពស្អាត ..................... ១២**
៥.៤.១. សូចនាករស្តីពីការបញ្ជ្រាបការយល់ដឹងស្តីពីកិច្ចការពារបរិស្ថាន និងភាពស្អាតដល់ប្រជាពលរដ្ឋក្នុងតំបន់ ..................... ១៣
៥.៤.២. សូចនាករស្តីពីការបញ្ជ្រាបការយល់ដឹងស្តីពីកិច្ចការពារបរិស្ថាន និងភាពស្អាតដល់ប្រតិបត្តករទេសចរណ៍ ... ..................... ១៣
៥.៤.៣. សូចនាករស្តីពីការបញ្ជ្រាបការយល់ដឹងអំពីការការពារបរិស្ថាន និងភាពស្អាតដល់ភ្ញៀវទេសចរ ..................... ១៣
**៥.៥. សូចនាករស្តីពីតំបន់បៃតង..................... ១៣**
៥.៥.១. ទំហំតំបន់បៃតងនៅក្នុងទីក្រុង..................... ១៤
៥.៥.២. សូចនាករស្តីពីការថែទាំ និងគ្រប់គ្រងតំបន់បៃតង ..................... ១៤
**៥.៦. សូចនាករស្តីពីសុវត្ថិភាពសុខាភិបាល សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង..................... ១៤**
៥.៦.១. សុវត្ថិភាពសុខាភិបាល ..................... ១៤
៥.៦.២. សុវត្ថិភាព និងសន្តិសុខនៅក្នុងទីក្រុង ..................... ១៤
៥.៦.៣. ការទប់ស្កាត់ឧក្រិដ្ឋកម្ម និងជម្រុញការអនុវត្តច្បាប់ (ពេស្យាចារកុមារ គ្រឿងញៀនជាដើម)....១៥
៥.៦.៤. យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ ..................... ១៥
**៥.៧. សូចនាករនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទ្រទ្រង់ទេសចរណ៍..................... ១៥**

៥.៧.១.ផែនការសម្រាប់វិស័យទេសចរណ៍.......... ១៦
៥.៧.៣.ទីតាំងនៃមជ្ឈមណ្ឌលផ្សារទំនើប និងហាងលក់រាយ .......... ១៦
៥.៧.៤. តំបន់សម្រាកលំហែ (តំបន់ទេសចរណ៍ ឧទ្យានសាធារណៈ កីឡា និងការកំសាន្ត ... ).......... ១៦
៥.៧.៥. កម្រិតនៃពេញចិត្តរបស់ភ្ញៀវទេសចរ.......... ១៦
**៦. ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន-លក្ខណៈវិនិច្ឆ័យ.......... ១៦**
៦.១.តារាងវាយតម្លៃលើសូចនាករចំនួន០៥ នៃការគ្រប់គ្រងបរិស្ថាន.......... ១៦
៦.២.តារាងវាយតម្លៃលើសូចនាករចំនួន០៤ នៃភាពស្អាត.......... ២០
៦.៣.តារាងវាយតម្លៃលើសូចនាករចំនួន០៥ នៃការគ្រប់គ្រងកាកសំណល់.......... ២១
៦.៤.តារាងវាយតម្លៃលើសូចនាករចំនួន០៣ នៃការបញ្ជ្រាបការយល់ដឹងអំពីការការពារបរិស្ថាន និងសូចនាករនៃភាពស្អាត.......... ២៣
៦.៥.តារាងវាយតម្លៃលើសូចនាករចំនួន០២ នៃតំបន់បៃតង.......... ២៥
៦.៦.តារាងវាយតម្លៃលើសូចនាករចំនួន០៤ នៃសុវត្ថិភាពសុខាភិបាល និងសន្តិសុខ និង សុវត្ថិភាពទីក្រុង... ២៥
៦.៧.តារាងវាយតម្លៃលើសូចនាករចំនួន០៥ នៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍.......... ២៧
**៧.ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន-ឡាបិល.......... ២៩**
៧.១.ឡាបិល.......... ២៩
៧.២.ពានរង្វាន់.......... ២៩
៧.៣. ដំណើរការនៃការវាយតម្លៃ .......... ២៩

## ១. បុព្វកថា

ការរៀបចំបង្កើតស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន (ASEAN Clean Tourist City Standard- ACTCS) រៀបចំឡើងក្នុងគោលបំណងដើម្បីផ្តល់នូវវិធីសាស្រ្តមួយដល់ប្រទេសសមាជិកអាស៊ាន ក្នុងការលើកកម្ពស់គុណភាពទេសចរណ៍នៅក្នុងទីក្រុងឱ្យមានលក្ខណៈល្អប្រសើរ ការបង្កើននូវភាពប្រកួតប្រជែងទីផ្សារ និងថែមទាំងធ្វើឱ្យស្ថានភាពរស់នៅរបស់ប្រជាជនក្នុងតំបន់មានលក្ខណៈល្អប្រសើរតាមរយៈការកាត់បន្ថយភាពក្រីក្រ។ ស្តង់ដានេះក៏ត្រូវបានរៀបចំឡើងដើម្បីការពារបរិស្ថាន ដែលឆ្លើយតបនឹងបញ្ហាបំរែបំរួលអាកាសធាតុ និងចូលរួមដល់ការអភិវឌ្ឍទីក្រុងអាស៊ានប្រកបដោយនិរន្តរភាព។ វាមានសារៈសំខាន់ណាស់ក្នុងការទទួលស្គាល់ថា **ផែនការយុទ្ធសាស្រ្តទេសចរណ៍អាស៊ាន ២០១១-២០១៥** (ATSP) បានចង្អុលបង្ហាញពីការពង្រឹងសមត្ថភាពទេសចរណ៍អាស៊ានដើម្បីឆ្លើយតបទៅនឹងបញ្ហាបំរែបំរួលអាកាសធាតុ ដែលជាសកម្មភាពអាទិភាពមួយក្នុងចំណោមសកម្មភាពជាអាទិភាពទាំងអស់ដើម្បីសម្រេចបាននូវទិសដៅយុទ្ធសាស្រ្តក្នុងការបង្កើនគុណភាពសេវា និងសម្បទាទ្រទ្រង់នានានៅក្នុងតំបន់។

ស្តង់ដានេះផ្អែកទៅលើបណ្តុំនៃសូចនាករដែលនឹងធ្វើការវាយតម្លៃអំពីកម្រិតស្ថានភាពនិរន្តរភាពរបស់ទីក្រុងអាស៊ានបច្ចុប្បន្ន គុណភាពទេសចរណ៍ដែលប្រទេសសមាជិកផ្តល់ទៅឱ្យភ្ញៀវទេសចរ និងកំណត់នូវចំនុចខ្វះខាតណាដែលនឹងត្រូវបានធ្វើឱ្យបានល្អប្រសើរឡើង។ ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាននេះ គឺជាស្តង់ដាគោលសម្រាប់ប្រទេសសមាជិកអាស៊ានទាំងអស់ធ្វើការប្រៀបធៀប ដើម្បីឆ្ពោះទៅរកការសម្រេចឱ្យបាននូវគោលដៅមួយប្រកបដោយការពេញចិត្តកាន់តែខ្លាំងពីភ្ញៀវទេសចរ ចំនួនអ្នកមកទស្សនាកាន់តែច្រើនជាងមុន និងការផ្តល់នូវលក្ខខណ្ឌដ៏ល្អប្រសើរសម្រាប់ប្រជាជនក្នុងមូលដ្ឋាន។

## ២. សេចក្តីផ្តើម

ទេសចរណ៍នៅក្នុងតំបន់អាស៊ីអាគ្នេយ៍មានការអភិវឌ្ឍ និងរីកចម្រើនយ៉ាងលឿន ខណៈពេលដែលតំបន់នេះ កំពុងក្លាយជាទិសដៅទេសចរណ៍ដ៏សំខាន់មួយក្នុងចំណោមទិសដៅចំបងនានានៅលើផែនទីទេសចរណ៍ពិភពលោក។ ទេសចរណ៍ត្រូវបានចាត់ទុកថាជាវិស័យសំខាន់បំផុតមួយក្នុងចំណោមវិស័យអាទិភាពដទៃទៀតសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងតំបន់។

រាល់កិច្ចពិភាក្សាទាំងឡាយដែលផ្តោតលើការអភិវឌ្ឍសេដ្ឋកិច្ច កំណើនមិនមែនជាគោលដៅចម្បងនោះទេ គោលបំនងមូលដ្ឋាននៃការអភិវឌ្ឍគួរតែមិនមែនផ្តោតតែលើកំណើននោះទេ តែគួរតែផ្តោតលើការរីកចម្រើនដ៏ធំទូលាយនៃកម្រិតជីវភាពរស់នៅ។ ក្នុងន័យនេះ កំណើនមិនមែនជារឿងដែលល្អឥតខ្ចោះសម្រាប់គាំទ្រល្បឿន និងទំហំនៃការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌនៃការរស់នៅប្រចាំថ្ងៃ។ ប៉ុន្តែខណៈដែលកំណើនអាចនឹងមិនមានលក្ខណៈគ្រប់គ្រាន់ការទទួលបានជោគជ័យលើផ្នែកសេដ្ឋកិច្ច វានៅតែជាកត្តាដ៏ចាំបាច់មួយ។ នៅក្នុងសង្គមជាទូទៅ វឌ្ឍនភាពសេដ្ឋកិច្ច-សង្គម មិនអាចកើតមានឡើយ ប្រសិនបើគ្មានកំណើនការងារ ប្រាក់ចំណូល និងទ្រព្យធន។ ដូច្នេះ ទាំងបរិមាណ និងគុណភាពនៃកំណើនគឺជាបញ្ហាសំខាន់។ គោលបំណងចុងក្រោយបំផុតគឺធ្វើយ៉ាងណាសម្រេចឲ្យបានកំណើនដ៏ធំមួយ **ខះ**កំណើនដ៏ខ្លាំងមួយដែលមាន ***តុល្យភាព*** ប្រកបដោយ ***ភាពធន់*** និង***ស្ថេរភាព***ជាជាងធ្វើឲ្យមានវិសមភាពកាន់តែធ្ងន់ធ្ងរ ហើយនិងមាន***ភាពបៃតង*** ប្រកបដោយនិរន្តរភាពនៃការអភិវឌ្ឍដែលគិតគូរដល់បរិស្ថានយ៉ាងម៉ត់ចត់។ ដូច្នេះ ការអភិវឌ្ឍបៃតងត្រូវបានគេស្គាល់ថាជាគំរូថ្មីមួយដ៏ល្អឥតខ្ចោះក្នុងការបង្កើនល្បឿន ទំហំ ភាពធន់ និង និងវឌ្ឍនភាពនៃកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពឲ្យកាន់តែខ្លាំងជាងមុន។ វិស័យទេសចរណ៍អាចដើរតួជាគន្លឹះក្នុងការសម្រេចបាននូវកំណើនមួយដែលធានាបានទាំងបរិមាណ និងគុណភាព ។

ខណៈពេលដែលទីក្រុងទាំងអស់មានការអភិវឌ្ឍកាន់តែប្រសើរនៅក្នុងតំបន់រួចហើយនោះ ទីក្រុងមួយចំនួនទើបតែមានការរីកចំរើនខ្លាំងក្នុងការក្លាយជាគោលដៅទេសចរណ៍។ នេះគឺជាឱកាសដ៏ល្អឥតខ្ចោះដើម្បីជំរុញទីក្រុងទាំងអស់ឲ្យធ្វើការអភិវឌ្ឍខ្លួនទៅជាច្រកចូលទីមួយទទួលស្វាគមន៍ភ្ញៀវទេសចរនៅក្នុងប្រទេស។ វាពិតជាមានសារៈសំខាន់ណាស់សម្រាប់កិច្ចអភិវឌ្ឍន៍ទេសចរណ៍ទាំងកម្រិតថ្នាក់ជាតិ និងថ្នាក់តំបន់ក្នុងការរក្សា និងបង្កើនកេរ្តិ៍ឈ្មោះល្អ និងកិត្តិនាមរបស់ទីក្រុង *(ដែលជាមុខមាត់របស់ប្រទេសជាតិ)* ដែលពោរពេញទៅដោយភាពទាក់ទាញលើផ្នែកវប្បធម៌ ធម្មជាតិ និងផលិតផលដែលផលិតដោយប្រជាជន។

វាជាសារៈប្រយោជន៍ជាយុទ្ធសាស្ត្រមួយសម្រាប់ទីក្រុងទាំងឡាយក្នុងការអភិវឌ្ឍតំបន់ដ៏ស្រស់ស្អាតទាំងនោះ ធ្វើឲ្យមានបរិស្ថាន និងអនាម័យល្អស្អាត ពង្រីកតំបន់ទីក្រុង និងផ្សព្វផ្សាយរមណីយដ្ឋានដែលពួកគេមានដល់ភ្ញៀវទេសចរ។ យ៉ាងពិតណាស់ ការទទួលស្វាគមន៍ និងបដិសណ្ឋារកិច្ចភ្ញៀវទេសចរនៅក្នុងតំបន់ទីក្រុងមានសារៈសំខាន់ដោយសារតែរមណីយដ្ឋានទេសចរណ៍ជាច្រើនមានទីតាំងស្ថិតនៅក្នុងទីក្រុង និងតំបន់ជាយក្រុង។ អាជ្ញាធរក្នុងតំបន់ត្រូវតែគិតគូរជាដាច់ខាតអំពទិដ្ឋភាពបរិស្ថាន និងកម្រិតជីវភាពនៅក្នុងទីក្រុងរបស់ពួកគេ ប្រសិនបើពួកគេមានបំណងផ្តល់បដិសណ្ឋារកិច្ច និងបំពេញតម្រូវការរបស់ភ្ញៀវទេសចរ។ ការបង្ហាញ និងបង្កើតស្តង់ដាទីក្រុងស្អាតេសចរណ៍អាស៊ាននេះមានភាពចាំបាច់ដែលផ្តល់ឲ្យប្រទេសសមាជិកអាស៊ានទាំងអស់នូវស្តង់ដារួមមួយដើម្បីអាចសម្រេចបានតាមសេខក្តីពេញចិត្តរបស់ភ្ញៀវទេសចរ និងចំនួនភ្ញៀវទេសចរដ៏ច្រើនមកទស្សនាក្នុងតំបន់។

## ៣. ទិសាសភាព

ស្តង់ដានេះផ្តោតសំខាន់ទៅលើទីក្រុងទេសចរណ៍ដែលជាទីកន្លែងមានលំហូរអ្នកទេសចរច្រើន និងជារមណីយដ្ឋានទេសចរណ៍វប្បធម៌ ធម្មជាតិ និងកែច្នៃជាច្រើន។

សូចនាករសម្រាប់ការវាយតម្លៃក្នុង ACTCS នេះមានរាយដូចខាងក្រោម៖

- ការគ្រប់គ្រងបរិស្ថាន
- ភាពស្អាត
- ការគ្រប់គ្រងសំណល់
- ការពង្រឹងការយល់ដឹងអំពីការការពារបរិស្ថាន និងភាពស្អាត
- តំបន់បៃតង
- សុវត្ថិភាពសុខាភិបាល និងសុវត្ថិភាព សន្តិសុខទីក្រុង
- សម្បទា និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍

ប្រទេសជាសមាជិកអាស៊ានទាំង ១០ ដែលមានកម្រិតអភិវឌ្ឍន៏វិស័យទេសចរណ៍ខុសៗគ្នា មានចំនួន និងប្រភេទភ្ញៀវទេសចរមកទស្សនាខុសៗគ្នាដែលមានផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថានដែលបណ្តាលមកពីទេសចរណ៍ផ្សេងៗគ្នា និងប្រព័ន្ធគ្រប់គ្រង និងនយោបាយមានលក្ខណៈខុសគ្នាទៅតាមគោលនយោបាយច្បាប់ និងបទបញ្ញត្តិនានា។ ដូច្នេះដើម្បីធ្វើឲ្យស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ានទទួលបានជោគជ័យ និងមានភាពត្រឹមត្រូវអាចប្រើប្រាស់បាននៅតាមប្រទេសនីមួយៗ សូចនាករសម្រាប់ស្តង់ដាក្នុងតំបន់ត្រូវតែ៖

- អាចយកមកអនុវត្តបានជាទូទៅសម្រាប់ប្រទេសទាំងអស់
- ត្រូវបានទទួលស្គាល់ដោយរដ្ឋសមាជិកភាគច្រើន
- មានលក្ខណៈបត់បែន
- ងាយស្រួលសម្រាប់វាស់វែង និងគ្រប់គ្រង

ដោយសារតែស្តង់ដាសម្រាប់តំបន់នេះមានលក្ខណៈបត់បែន វាគួតែត្រូវបានកែសម្រួលជារៀងរាល់ **៣ ឆ្នាំម្តង**តាមតម្រូវការ។

## ៤. ពាក្យគន្លឹះ និងនិយមន័យ

ខាងក្រោមនេះជាពាក្យគន្លឹះ និងនិយមន័យនៃពាក្យដែលត្រូវបានប្រើប្រាស់ក្នុងស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន៖

### ៤.១. ភាពស្អាត

សំដៅទៅដល់បរិស្ថាន ភាពស្អាត និងអនាម័យ ក្នុងរមណីយដ្ឋានទេសចរណ៍ សណ្ឋាគារ ភោជនីយដ្ឋាន ទីសាធារណៈជាដើម មានភាពស្អាត និងអនាម័យ រួមទាំងគុណភាពខ្យល់ គុណភាពទឹកដែលអាចប្រើប្រាស់បាន និងប្រព័ន្ធគ្រប់គ្រង និងប្រមូលសំណល់រឹង និងរាវ។

### ៤.២. តំបន់បង់ប្រាក់សម្រាប់ការកកស្ទះ

សំដៅដល់តំបន់ដែលមានចរាចរណ៍ ឬមនុស្សលើសលប់ដែលបង្កឲ្យការធ្វើដំណើរមានសភាពយឺតយ៉ាវ ឬលំបាក។ យានយន្តដែលឆ្លងកាត់តំបន់នេះត្រូវតែបង់ប្រាក់។

## ៤.៣. យាន្តយន្តដែលគិតគូពីបរិស្ថាន

សំដៅយានយន្តដែលមានផលប៉ះពាល់តិចបំផុតទៅលើបរិស្ថានជាងយានយន្តដែលដើរដោយសាំង ឬប្រេងឥន្ទនៈ ឬក៏ប្រភេទយន្តយន្តដែលប្រើប្រាស់ប្រេងសាំងផ្សេងទៀត។ ប្រភេទយានយន្តបែបនេះត្រូវបានបង្កើតឡើងជាពិសេសដើម្បីកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថានធម្មជាតិ។

## ៤.៤. បទដ្ឋានគតិយុត្តស្តីពីបរិស្ថាន

សំដៅដល់បទបញ្ញា និងបទដ្ឋានគតិយុត្តដែលផ្តោតទៅលើការគ្រប់គ្រងផលប៉ះពាល់នានាលើបរិស្ថាន និងការការពារបរិស្ថានដូចជាការបំពុលខ្យល់ ការបំពុលទឹក ការបំពុលដោយសម្លេង ការប្រមូល និងគ្រប់គ្រងសំណល់ជាដើម។

## ៤.៥. តំបន់បៃតង

សំដៅដល់តំបន់នៅក្នុងទីក្រុងដែលសាធារណជនអាចទៅដល់ និងមានរៀបចំដាំលម្អដោយផ្កា ដើមឈើ ឬស្មៅជាដើម។

## ៤.៦. មណ្ឌលសុខភាព

សំដៅដល់ទីតាំងដែលមានផ្តល់សេវាសុខាភិបាល។ ជាទូទៅមណ្ឌលសុខភាពសំដៅទៅរកទីកន្លែងដែលមានការពិនិត្យព្យាបាល និងផ្តល់សេវាសុខាភិបាល។

## ៤.៧. សកម្មភាពខុសច្បាប់

គឺជាសកម្មភាពដែលប្រឆាំងនឹងច្បាប់ដូចជាឧក្រិដ្ឋកម្ម ការជួញដូរគ្រឿងញៀន ការបំផ្លាញសម្បត្តិវប្បធម៌ និងធម្មជាតិជាដើម។

## ៤.៨. បទដ្ឋាន

សំដៅទៅលើស្តង់ដានៃអកប្បកិរិយាដែលត្រូវកំនត់ជាច្បាប់ និងតម្រូវការដើម្បីជម្រុញអនុវត្តនៅក្នុងសង្គម។ កាន់តែជាក់ច្បាស់ជាងនេះ បទដ្ឋាននេះគឺជាវិធានការចាប់បង្ខំដោយច្បាប់។

## ៤.៩. កម្មវិធីដំណើរទស្សនាកំសាន្តរបស់ភ្ញៀវទេសចរដោយមានប្លង់ច្បាស់លាស់

គឺជាប្លង់ដែលរៀបចំដោយអាជ្ញាធរមូលដ្ឋាន ឬដោយការីទេសចរ ហើយប្លង់នេះបង្ហាញពីទីតាំងនៃរមណីយដ្ឋានទេសចរណ៍នានា។

## ៤.១០.ការបំពុល (ទឹក ខ្យល់ និងដោយសម្លេង)

សំដៅដល់សកម្មភាពទាំងឡាយណាដែលប្រជាពលរដ្ឋក្នុងមូលដ្ឋាន ភ្ញៀវទេសចរ អាជីវកម្មេះជាដើមដែលមិនបានប្រព្រឹត្តិទៅតាមលក្ខណៈស្តង់ដាជាតិ (រួមបញ្ចូលទាំងគុណភាពទឹក គុណភាពខ្យល់ និងកម្រិតសម្លេង)

## ៤.១១.តំបន់សាធារណៈ

សំដៅដល់កន្លែងដែលប្រជាពលរដ្ឋមូលដ្ឋាន និងភ្ញៀវទេសចរប្រមូលផ្តុំ (រួមបញ្ចូលទាំងអគាររដ្ឋបាលសម្រាប់ផ្តល់សេវាសាធារណៈ និងសម្ភារៈបរិក្ខានៅក្នុងតំបន់សាធារណៈដូចជាកៅអីវែងសម្រាប់អង្គុយ មធ្យោបាយធ្វើដំណើរសាធារណៈ ...)

### ៤.១២. ការបញ្ជ្រាបការយល់ដឹង

សំដៅដល់សកម្មភាពទាំងឡាយដែលមានធាតុចំនួន ០៣ដូចជាគោលបំណងនៃការបញ្ជ្រាបការយល់ដឹង ទិសដៅដែលត្រូវអនុវត្ត និងឯកសារគាំទ្រនានាដែលប្រើប្រាស់សម្រាប់ផ្តល់ព័ត៌មាន។ ការបញ្ជ្រាបការយល់ដឹងស្តីពីកិច្ចគាំពារបរិស្ថាន និងការថែរក្សារភាពស្អាតសំដៅធ្វើការពញ្ញាក់អារម្មណ៍ប្រជាពលរដ្ឋ ភ្ញៀវទេសចរ និងភាគីពាក់ព័ន្ធទាំងឡាយអោយយល់ដឹងពីអត្ថប្រយោជន៍នៃភាពស្អាត អនាម័យល្អ និងបរិស្ថានដែលមានផាសុខភាពល្អ។

### ៤.១៣. ការកែច្នៃ

សំដៅដល់ដំណើការនៃការកែច្នៃសម្ភារៈដែលប្រើប្រាស់រួច (សំណល់) ទៅជាផលិតផលថ្មី ដើម្បីទប់ស្កាត់ការចោលសំរាមដែលអាចកែច្នៃជាសំភារៈមានប្រយោជន៍បាន កាត់បន្ថយការប្រើប្រាស់ថាមពល កាត់បន្ថយការបំពុលដោយខ្យល់ (ចេញពីទីលានចាក់សំរាម) និងការបំពុលទឹក (ចេញពីការចាក់បំពេញដី) ដោយកាត់បន្ថយតម្រូវការនៃការបញ្ចេញចោលសំណល់ និងកាត់បន្ថយការបញ្ចេញនូវឧស្ម័នផ្ទះកញ្ចក់។

### ៤.១៤. ថាមពលកកើតឡើងវិញ

សំដៅដល់ទម្រង់នានារបស់ថាមពលដែលត្រូវបានគេទាញចេញពីថាមពលធម្មជាតិ ដូចជាព្រះអាទិត្យ ខ្យល់ រលក ឬក៏ធនធានធម្មជាតិកកើតឡើងវិញ មានលក្ខណៈផ្ទុយពីថាមពលដើរដោយឥន្ធនៈ។

### ៤.១៥. ការគ្រប់គ្រងហានិភ័យ

សំដៅយន្តការ និងការវាសវែងនានាដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចប្រើប្រាស់សម្រាប់ទប់ស្កាត់ និងគ្រប់គ្រងហានិភ័យ និងគ្រោះមហន្តរាយនានាដែលមិនបានរំពឹងទុក។

### ៤.១៦. ទីក្រុងទេសចរណ៍

សំដៅដល់ទីក្រុងដែលមានលំហូរភ្ញៀវទេសចរ និងជាទីកន្លែងដែលមានរមណីយដ្ឋានវប្បធម៌ ធម្មជាតិ និងកែច្នៃនានា។

### ៤.១៧. ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍

សំដៅសេវាកម្ម និងសម្បទានានាដែលមាននៅនឹងកន្លែងដែលអាចជួយសម្រួល និងធ្វើឲ្យការធ្វើដំណើរ និងវិស័យទេសចរណ៍ក្នុងទីក្រុងមានលក្ខណៈល្អប្រសើរ រួមមានទាំងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់នានាដូចជាមណ្ឌលព័ត៌មានទេសចរណ៍ ស្លាកសញ្ញា ជាដើម។

### ៤.១៨. នគរបាលទេសចរណ៍

សំដៅដល់អាជ្ញាធរដែលបាន ហ្វឹកហាត់ជាពិសេសសម្រាប់ទទួលខុសត្រូវលើការដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹងភ្ញៀវទេសចរនៅក្នុងទីក្រុង។

### ៤.១៩. ផែនការទីក្រុង

គឺជាផែនការនានាដែលបង្កើតឡើងដោយអាជ្ញាធរក្រុងដើម្បីធ្វើឲ្យប្រាកដថាការអភិវឌ្ឍទីក្រុងមាននិរន្តរភាពដូចជាគម្រោងប្រើប្រាស់ដី ការកំណត់តំបន់ គម្រោងអំពីបរិស្ថាន និងគម្រោងលើមធ្យោបាយធ្វើដំណើរ។

### ៤.២០. ការគ្រប់គ្រងសំណល់

សំដៅដល់វិធានការដែលធ្វើឡើងដោយអាជ្ញាធរក្រុងដើម្បីប្រមូល បែងចែក និងទុកដាក់សំណល់រឹង និងរាវទៅតាមវិធីសាស្ត្រដែលសមរម្យ និងមានប្រសិទ្ធភាព។

## ៥. ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន- សូចនាករ

### ៥.១. សូចនាករស្តីពីការគ្រប់គ្រងបរិស្ថាន

ការគ្រប់គ្រងបរិស្ថាន សំដៅទៅដល់បណ្តុំនៃយុទ្ធសាស្ត្រដែលគិតគូរពីផលប៉ះពាល់ទៅលើបរិស្ថានដែលមានប្រភពចេញពីសកម្មភាពអភិវឌ្ឍន៍របស់ប្រទេសមួយ ទីក្រុងមួយ ឬដើម្បីរៀបចំគម្រោងអភិវឌ្ឍន៍ណាមួយ។ ការវាយតម្លៃពីផលប៉ះពាល់លើបរិស្ថានចេញពីសកម្មភាពនីមួយៗត្រូវបានបង្កើតក្នុងកម្រិតផ្សេងៗគ្នា និងវិធីខុសប្លែកពីគ្នា។ ក្នុងពេលជាមួយគ្នានោះដែរ សកម្មភាពទាំងឡាយដែលយើងអាចដាក់ដំណើការដើម្បីឆ្លើយតបទៅនឹងបញ្ហាមួយចំនួនដូចជា ការបញ្ជ្រាបការយល់ដឹង ការរឹតបន្តឹង ឬការហាមប្រាមនានា និងគម្រោងអភិវឌ្ឍន៍តំបន់ទីក្រុងជាដើម។

សូចនាករនេះ គឺជាធាតុដ៏សំខាន់ដែលមិនអាចប្រកែកបានដែលយើងបានឃើញនៅក្នុងគោលនយោបាយទាំងឡាយដែលពាក់ព័ន្ធទៅនឹងការបង្កើន និងធ្វើឲ្យស្តង់ដារស់នៅរបស់សាធារនណជនមានភាពល្អប្រសើ។ ពិតណាស់ថា យើងអាចនិយាយាបានថាសូចនាករគោលប្រមូលផ្តុំនូវរាល់ធាតុជាច្រើនដែលបង្ហាញពីរង្វាស់នៃស្ថានភាពបច្ចុប្បន្នរបស់បរិស្ថានជុំវិញនៅក្នុងមជ្ឍដ្ឋានរស់នៅ ដោយផ្តោតទៅលើផ្នែកសំខាន់នៃធាតុសំខាន់របស់សុខភាពសាធារណៈដូចជា គុណភាពខ្យល់ គុណភាពទឹកសម្រាប់ប្រើប្រាស់ជាទូទៅ គុណភាពទឹកសម្រាប់បរិភោគជាដើម។ ដូច្នេះហើយស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ានមានគោលបំណងផ្សព្វផ្សាយ និងជម្រុញទីក្រុងទាំងអស់ដើម្បីប្រកាស និងពញ្ញាក់ស្មារតីប្រជាពលរដ្ឋជុំវិញសមត្ថភាពយល់ដឹងរបស់ពួកគាត់ និងភ្ញៀវទេសចរទៅកាន់ទីក្រុងរបស់គាត់ឲ្យយល់ដឹងស្តីពីស្ថានភាពបរិស្ថានជុំវិញទីកន្លែងដែលពួកគេរស់នៅ និងកម្សាន្ត។

បន្ថែមពីនេះ សូចនាករលំអិតនៃសូចនាករនេះមានគោលបំណងជម្រុញរាល់ទីក្រុងបេក្ខភាពទាំងអស់ឲ្យចាប់ផ្តើមដាក់ចេញនូវវិធានការទប់ស្កាត់សកម្មភាពនានាដែលមានឥទ្ធិពលប៉ះពាល់ទៅលើស្តង់ដារស់នៅ និងជំរុញការអនុវត្តគម្រោងអភិវឌ្ឍន៍ទីក្រុងរបស់ពួកគេដើម្បីឲ្យដឹងច្បាស់លាស់ពីផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមានដែលអាចបណ្តាលមកពីសកម្មភាពអភិវឌ្ឍន៍ទីក្រុងទាំងនោះ។ សូចនាករនេះក៏មានបំណងបញ្ជ្រាបការយល់ដឹងពីទីក្រុងស្តីពីការប្រើប្រាស់ថាមពលកើតឡើងវិញ។

#### ៥.១.១. ផែនការទីក្រុង

សូចនាករលម្អិតនេះវាយតម្លៃថាតើមានគម្រោងប្រើប្រាស់ដី ការបែងចែកតំបន់ គម្រោងគម្រោងការពារបរិស្ថាន និងមធ្យោបាយដឹកជញ្ជូនត្រូវបានអនុវត្តដោយអាជ្ញាធរក្រុងដើម្បីធានាការរីកចម្រើនរបស់ក្រុងប្រកបដោយនិរន្តរភាព និងមានការគ្រប់គ្រង។

#### ៥.១.២. បទបញ្ញត្តិស្តីពីបរិស្ថាន

សូចនាករលម្អិតនេះវាយតម្លៃថាតើមានបទបញ្ញត្តិស្តីពីបរិស្ថានសម្រាប់គ្រប់គ្រងដំណើការអាជីវកម្មទេសចរណ៍ ហើយបទបញ្ញត្តិទាំងនោះត្រូវបានជម្រុញដោយការអនុម័តរបស់អាជ្ញាធរក្នុងតំបន់ឬទេ (ឧទា. សម្រាប់បទបញ្ញត្តិលើគម្រោង ច្បាប់ស្តីពីបទបញ្ញាតិស្តីពីការធ្វើប្រព្រឹត្តិកម្មសំណល់។

### ៥.១.៣. ការបំពុល (ទឹក ខ្យល់ និងសំលេង)

សូចនាករលម្អិតនេះវាយតម្លៃលើកម្រិតបំពុលរបស់ទឹក និងមានបទដ្ឋានទទួលស្គាល់ដែលកំណត់ដោយបទបញ្ញត្តិផ្លូវការ។ វាសំដៅទៅលើទន្លេ (ដូចជាខេត្តសៀមរាប ឬទីក្រុងភ្នំពេញ ប្រទេសកម្ពុជា) ទឹកសមុទ្រនៅតាមតំបន់ឆ្នេរសមុទ្រ (ដូចជាខេត្តព្រះសីហនុ និងខេត្តកែប ប្រទេសកម្ពុជា) រួមទាំងទឹកសម្រាប់បរិភោគផងដែរ។

សូចនាករលម្អិតនេះក៏វាយតម្លៃគុណភាពខ្យល់នៅក្នុងទីក្រុង និងវិធានការដែលបានដាក់ឲ្យប្រើដើម្បីធ្វើវាឲ្យមានលក្ខណៈល្អប្រសើ (ឧទា. ការកាត់បន្ថយការកកស្ទះចរាចរណ៍ ការប្រើប្រាស់ប្រេងឥន្ធនៈ) កម្រិតនៃការបំពុលដោយសម្លេង និងច្បាប់នានាដែលដាក់ចេញ និងអនុវត្តដើម្បីរក្សាសំលេងរំខានឲ្យស្ថិតក្នុងលំនាំច្បាប់។

### ៥.១.៤. មធ្យោបាយធ្វើដំណើរដែលគិតគូរពីបរិស្ថាន

សូចនាករលម្អិតនេះសំដៅដល់ប្រភេទមធ្យោបាយធ្វើដំណើរដែលត្រូវបានប្រើប្រាស់នៅក្នុងទីក្រុង (ទាំងរដ្ឋ និងឯកជន) និងផលប៉ះពាល់របស់វាទៅដល់បរិស្ថាន។ ការប្រើប្រាស់យានជំនិះដែលគិតគូដល់បរិស្ថានត្រូវបានលើកទឹកចិត្ត (រថយន្តក្រុងដែលមានបំពាក់ប្រព័ន្ធគ្រប់គ្រងការបំពុល ឡានដើរដោយថាមពលអគ្គិសនី រួមទាំងមានតំបន់បង់ថ្លៃបន្ទុកការកកស្ទះ)។

### ៥.១.៥. ការប្រើប្រាស់ថាមពលប្រកបដោយនិរន្តរភាព

សូចនាករនេះសំដៅទៅដល់ការសន្សំសំចៃថាមពល និងឧបករណ៍ដែលមានប្រសិទ្ធភាពប្រើប្រាស់នៅក្នុងអាជីវកម្មទេសចរណ៍ (អំពូលភ្លើងគិតគូពីបរិស្ថាន ប្រើប្រាស់សោរជាកាតផ្តាច់ចរន្តអគ្គិសនីជាដើម) ការប្រើប្រាស់ថាមពលកើតឡើងវិញ (ពន្លឺព្រះអាទិត្យ ខ្យល់ ជាដើម) និងការបញ្ជ្រាប និងការប្តេជ្ញារបស់ក្រុមហ៊ុនទេសចរណ៍ដើម្បីសន្សំសំចៃថាមពល និងប្រើប្រាស់ឲ្យមានប្រសិទ្ធភាព។

## ៥.២. សូចនាករស្តីពីភាពស្អាត

ទីកន្លែងប្រជុំជនសាធារណៈគឺជាកន្លែងដែលមនុស្សម្នាអាចទំនាក់ទំនងគ្នាបាន។ ភាពស្អាតនៅតាមទីសាធារណៈត្រូវពឹងផ្អែកលើអាកប្បកិរិយាបុគ្គល និងការយកចិត្តទុកដាក់ដើម្បីថែរក្សាទីកន្លែងទាំងនោះ។ ក្រៅពីនេះ ភាពស្អាតនៅតាមទីសាធារណៈគឺជាកត្តាសំខាន់ដែលមានឥទ្ធិពលទៅលើសុខុមាលភាពរបស់ប្រជាជនទូទៅ។ ជាការពិត ភាពស្អាតនៅតាមសាធារណៈចូលរួមចំណែកយ៉ាងសំខាន់ទៅដល់ការបង្កើនស្តង់ដារស់នៅ និងសម្រស់របស់ទីក្រុងឲ្យបានល្អប្រសើ ដែលភាពស្អាតនេះតម្រូវឲ្យមានដែលមិនអាចជៀសបានសម្រាប់អ្នកទេសចរ។

នៅក្នុងសូចនាករនេះ យើងពិចារណាទៅលើភាពស្អាតនៅតាមទីប្រជុំជនសាធារណៈដូចជាអគារសាធារណៈ មជ្ឈមណ្ឌលព័ត៌មាន តំបន់បៃតង មជ្ឈមណ្ឌលពាណិជ្ជកម្ម រមណីយដ្ឋាន និងសួនច្បារ ផ្លូវសំខាន់ៗ និងបង្គន់សាធារណៈជាដើម។

សូចនាករនេះផ្តោតទៅលើភាពជាក់ស្តែងនៃទស្សនីយភាពទូទៅនៅតាមទីប្រជុំជនសាធារណៈរបស់ទីក្រុង និងវាស់វែងពីកម្រិតនៃការយកចិត្តទុកដាក់ទៅលើភាពស្អាតរបស់អាជ្ញាធរក្រុង។ ជាទូទៅ អ្នកមកទស្សនានៅទៅក្រុងក៏ដូចជាសាធារណជនត្រូវបានទាក់ទាញដោយសោភ័ណភាពរបស់ទីកន្លែងទាំងនោះ។

### ៥.២.១. ភាពស្អាតនៅតាមទីកន្លែងសាធារណៈ

សូចនាករលំអិតនេះជាធាតុសំខាន់មួយដើម្បីបង្ហាញពីចំនុចវិជ្ជមានទៅកាន់ភ្ញៀវទេសចរក៏ដូចជាប្រជាពលរដ្ឋក្នុងតំបន់ និងផ្នែកឯកជន។ ភាពស្អាតនៅតាមតំបន់ និងអគារសាធារណៈ តំបន់បៃតង ផ្សារ ស្ថានីយ៍ មជ្ឈមណ្ឌលព័ត៌មាន គួរតែត្រូវបានវាយតម្លៃដោយអាជ្ញាធរក្នុងតំបន់ និងការផាកពិន័យគួត្រូវបានដាក់ចេញដើម្បីពង្រឹងការអនុវត្តច្បាប់ទាំងឡាយ។ ទំហំនៃសម្ភារៈបរិក្ខារដូចជាចំនួនធុងសម្រាមនៅក្នុងតំបន់សាធារណៈ និងការថែរក្សាពួកវាជាប្រចាំគួរតែត្រូវមានការគិតគូរផងដែរ។

### ៥.២.២. ភាពស្អាតនៅតាមបង្គន់សាធារណៈ

សូចនាករលំអិតនេះសំដៅទៅដល់ចំនួនបង្គន់សាធារណៈនៅតាមរមណីយដ្ឋានទេសចរណ៍នៅក្នុងទីក្រុង ភាពញឹកញាប់ និងគុណភាពនៃការថែទាំវា។ កិច្ចការនេះផ្សារភ្ជាប់ទៅនឹងស្តង់ដាបង្គន់សាធារណៈអាស៊ាន។

### ៥.២.៣. ភាពស្អាតនៅតាមរមណីយដ្ឋានទេសចរណ៍ (សារមន្ទីរ ប្រាសាទ សួនឧទ្យាន ឆ្នេរសមុទ្រជាដើម)

សូចនាករលំអិតនេះវាយតម្លៃថាមានការបំពាក់ធុងសំរាមគ្រប់គ្រាន់ឬទេនៅតាមរមណីយដ្ឋានទេសចរណ៍ ភាពញឹកញាប់ក្នុងការប្រមូល និងការបញ្ចេញចោលសំណល់ និងភាពស្អាតជាទូទៅ និងការថែទាំបរិវេណជុំវិញរមណីយដ្ឋានទេសចរណ៍។ លិខិតបញ្ជាក់ពីការផាកពិន័យចំពោះការមិនគោរពច្បាប់គួរត្រូវបានរៀបចំផងដែរ។

### ៥.២.៤. ភាពស្អាតតាមផ្លូវសំខាន់ៗ

សូចនាករលំអិតមួយនេះវាយតម្លៃពីស្ថានភាពនៅតាមផ្លូវសំខាន់ៗនៅក្នុងទីក្រុង ព្រមទាំងផ្លូវពីទីក្រុងមួយទៅទីក្រុងមួយផ្សេងទៀតថា តើផ្លូវទាំងនោះមានភាពស្អាតជាប្រចាំឬទេហើយមានសម្ភារៈគ្រប់គ្រាន់សមរម្យឬនៅ(ឧទា.ការបំពាក់ធុងសំរាមឲ្យបានគ្រប់គ្រាន់នៅតាមបណ្តោយផ្លូវ)។

## ៥.៣. សូចនាករស្តីពីការគ្រប់គ្រងសំណល់

ការគ្រប់គ្រងសំណល់សំដៅលើការប្រមូល និងទុកដាក់សំណល់។ សំណល់គឺជាលទ្ធផលចេញពីសកម្មភាពរបស់ប្រជាពលរដ្ឋក្នុងការបំពេញនូវតម្រូវការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។ ការគ្រប់គ្រងសំណល់នៅក្នុងបរិបទនេះមានគោលបំណងសំខាន់ក្នុងការចូលរួមកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានដល់សុខភាពរបស់ប្រជាពលរដ្ឋ បរិស្ថាន និងសោភ័ណភាពទីក្រុង។

ជាការពិតចាប់តាំងពីពាក់កណ្តាលសតវត្សន៍ទី២០មក បរិមាណសំណល់នៅជុំវិញពិភពលោកកើនឡើងគួរឲ្យកត់សម្គាល់ (ផ្សារភ្ជាប់ទៅនឹងកំណើនអភិវឌ្ឍន៍ឧស្សាហកម្ម)។ ផលប៉ះពាល់អវិជ្ជមានពីសំណល់ឧស្សាហកម្មគឺជាបញ្ហាសកល។ បើទោះបីជាការគ្រប់គ្រងសំណល់ និងប្រព័ន្ធចម្រោះកម្រិតសកលលោក និងកម្រិតជាតិជួបប្រទះនឹងបញ្ហាប្រឈមជាច្រើនយើងត្រូវតែដាក់ដំណើការប្រព័ន្ធដែលសាមញ្ញ និងងាយស្រួលមួយនៅតាមទីក្រុងទាំងអស់នេះ។

ស្តង់ដានេះ ទាមទាឲ្យទីក្រុងទាំងអស់ដាក់ដំណើការនូវគម្រោងគ្រប់គ្រងសំណល់ឲ្យមានប្រសិទ្ធភាពរួមទាំងការប្រមូល និងប្រព្រឹត្តកម្មសំណល់រឹង និងសំណល់រាវ ព្រមទាំងដាក់ចេញយុទ្ធនាការបញ្ជ្រាប់ការយល់ដឹងដែលពាក់ព័ន្ធនានាផងដែរ។

### ៥.៣.១. ការប្រមូលសំណល់រាវ

សូចនាករលម្អិតនេះវាយតម្លៃចំពោះអង្គភាពរដ្ឋលើការងារប្រមូលសំណល់រាវ និងកំណត់ភាគរយចំនួនប្រជាពលរដ្ឋដែលភ្ជាប់បណ្តាញគ្រប់គ្រងសំណល់រាវ។ នៅក្នុងតំបន់ដែលមិនមានបណ្តាញបញ្ចេញសំណល់រាវ សូចនាករនេះនឹងវាយតម្លៃពីរបៀបដែលសំណល់រាវទាំងនោះត្រូវបានប្រមូល និងភាពញឹកញាប់នៃការប្រមូល។

### ៥.៣.២.ការប្រមូលសំណល់រឹង

សូចនាករលម្អិតនេះវាយតម្លៃចំពោះអង្គភាពសាធារណៈដើម្បីប្រមូលសំណល់រឹង និងកំណត់ភាគរយចំនួនប្រជាពលរដ្ឋដែលភ្ជាប់បណ្តាញប្រមូលសំណល់រឹង (វត្តមាននៃតំបន់បញ្ចេញចោលសំណល់នៅជិតទីកន្លែងដែលប្រជាពលរដ្ឋរស់នៅ)។ នៅក្នុងតំបន់ដែលមិនមានបណ្តាញប្រមូលសំណល់រឹង សូចនាករនេះនឹងវាយតម្លៃពីរបៀបដែលសំណល់រឹងទាំងនោះត្រូវបានប្រមូល និងភាពញឹកញាប់នៃការប្រមូល។

### ៥.៣.៣.ការស្តុក និងប្រព្រឹត្តកម្មសំណល់រាវ

សូចនាករលម្អិតវាយតម្លៃលើលទ្ធភាពនៃវត្តមាននៃតំបន់ស្តុកសំណល់រាវដែលប្រជាពលរដ្ឋទូទៅអាចប្រើប្រាស់បានតាមរយៈការប្រមូលដោយអាជ្ញាធរ និងលទ្ធភាពនៃឧបករណ៍ស្តុកសំណល់រាវជាលក្ខណៈឯកជននៅតាមសម្បទាទេសចរន៍នានា (ដូចជា អាងចម្រោះ Septic Tank) ហើយនឹងឧបករណ៍ដែលមានសម្រាប់ធ្វើប្រព្រឹត្តកម្មសំណល់ (ឧទា. រោងចក្រប្រព្រឹត្តកម្មសំណល់)។

### ៥.៣.៤. កាស្តុក និងប្រព្រឹត្តកម្មសំណល់រឹង

សូចនាករលម្អិតវាយតម្លៃលើលទ្ធភាពនៃវត្តមាននៃកន្លែងស្តុកសំណល់រឹងដែលប្រជាពលរដ្ឋទូទៅ និងប្រតិបត្តិករទេសចរណ៍អាចប្រើប្រាស់បានតាមរយៈការប្រមូលដោយអាជ្ញាធរ (ទីលានចាក់សំរាមជាឧទាហរណ៍)។ វិធីសាស្ត្រដែលត្រូវបានប្រើប្រាស់សម្រាប់ធ្វើប្រព្រឹត្តកម្មសំណល់រឹង ក៏ត្រូវបានបញ្ចូលក្នុងការវាយតម្លៃដែរ(រោងចក្រប្រព្រឹត្តកម្មសំណល់ និងកែច្នៃ ការដុត ការកប់សំណល់ជាដើម)។

### ៥.៣.៥.ការកែច្នៃឡើងវិញ

សូចនាករសម្អិតនេះវាយតម្លៃថាតើអាជ្ញាក្នុងតំបន់បានជម្រុញលើកទឹកចិត្តឲ្យមានការកែច្នៃឡើងវិញឬទេ ហើយមានប្រព័ន្ធសម្រាប់ប្រមូល និងកែច្នៃសម្ភារៈទាំងនោះទេ។ វាក៏សំដៅទៅលើការបញ្ជ្រាបការយល់ដឹងស្តីពីសារៈសំខាន់នៃការកែច្នៃឡើងវិញទៅដល់ប្រជាពលរដ្ឋ និងជាពិសេសទៅដល់អ្នកផ្តល់សេវាកម្មទេសចរណ៍(ដូចជាសណ្ឋាគារ ភោជនីយដ្ឋាន សហការីទេសចរណ៍)។

## ៥.៤. សូចនាករស្តីពីការបញ្ជ្រាបការយល់អំពីកិច្ចការពារបរិស្ថាន និងភាពស្អាត

ការបញ្ជ្រាបការយល់ដឹងសំដៅដល់សកម្មភាពដែលរួមមានធាតុសំខាន់ៗចំនួន ០៣ ដូចជា គោលបំណងនៃការបញ្ជ្រាបការយល់ដឹង គោលដៅដែលត្រូវអនុវត្ត និងឯកសារយោងដែលត្រូវប្រើប្រាស់សម្រាប់ផ្តល់ព័ត៌មាន។ ការបញ្ជ្រាបការយល់ដឹងស្តីពីកិច្ចការពារបរិស្ថាន និងភាពស្អាតគឺជាការក្រើនរំលឹកដាស់តឿនដល់ប្រជាពលរដ្ឋក្នុងតំបន់ ភ្ញៀវទេសចរ និងភាគីពាក់ព័ន្ធអំពីផលប្រយោជន៍នៃភាពស្អាត អនាម័យ និងបរិស្ថានស្អាត។

ការបញ្ជ្រាបការយល់ដឹងត្រូវបានចាត់ទុកជាទម្រង់មួយនៃការផ្ទេរចំណេះដឹង ឬការយល់ដឹងទូទៅផ្សេងៗ (ជាទូទៅវាកើតចេញពីសកម្មភាពជាទំលាប់ដដែលៗ)។ ដូចនេះគោលបំណងនៃការបញ្ជ្រាបការយល់ដឹងនេះ គឺចង់ផ្សព្វផ្សាយព័ត៌មានអំពីការបំផ្លិចបំផ្លាញដែលចេញពីការអនុវត្តខុសឆ្គងប្រចាំថ្ងៃ ហើយនឹងចង់ណែនាំពីឥរិយាបថ និងការអនុវត្តល្អៗមួយចំនួនដែលអាចចូលរួមធ្វើឲ្យជីវិត និងការរស់នៅកាន់តែល្អប្រសើរឡើង។ ស្តង់ដាទីក្រុងទេសចរណ៍ស្អាតផ្តោតជាពិសេសដល់ការក្រើនរំលឹកដល់ប្រជាពលរដ្ឋក្នុងតំបន់ អ្នកផ្តល់សេវាទេសចរណ៍ និងភ្ញៀវទេសចរឲ្យយកចិត្តទុកដាក់លើបរិស្ថាន និងភាពស្អាត។

ការបញ្ជ្រាបការយល់ដឹងគឺជាយន្តការមួយយ៉ាងសំខាន់សម្រាប់ជម្រុញការអនុវត្តស្តង់ដាទីក្រុងស្អាត។ យន្តការនេះត្រូវបានចាត់ទុកជាសកម្មភាពគន្លឹះដែលទីក្រុងទាំងអស់ត្រូវផ្តួចផ្តើមដើម្បីក្រើនរំលឹកទៅដល់ភាគីពាក់ព័ន្ធទាំងអស់ឲ្យយល់ដឹង និងចាប់ផ្តើមចូលរួមអនុវត្តតាមស្តង់ដាជាបណ្តើរៗ។ វាអាចមានទម្រង់ផ្សេងៗគ្នា។ យើងមិនតម្រូវឲ្យមានសកម្មភាពជាក់លាក់ណាមួយទេ ដោយផ្តល់លទ្ធភាពទៅដល់ទីក្រុងទាំងអស់ជាអ្នកសម្រេចជ្រើសយកវិធីសាស្ត្រណាមួយ ដែលសក្តិសមនឹងស្ថានភាពរបស់ខ្លួន។ ដោយឡែក ការវាយតម្លៃត្រូវផ្តោតលើប្រសិទ្ធភាព និងភាពញឹកញាប់របស់សកម្មភាពដែលបានដាក់ចេញ។ ការបញ្ជ្រាបការយល់ដឹងអាចនឹងត្រូវបានអនុវត្តក្រោមកិច្ចសហការជាមួយនឹងភាគីពាក់ព័ន្ធផ្សេងៗដូចជាអង្គការអន្តរជាតិ ឬអង្គការក្រៅរដ្ឋាភិបាលជាដើម។

### ៥.៤.១. សូចនាករស្តីពីការបញ្ជ្រាបការយល់ដឹងស្តីពីកិច្ចការពារបរិស្ថាន និងភាពស្អាតដល់ប្រជាពលរដ្ឋក្នុងតំបន់

សូចនាករលម្អិតនេះនឹងវាយតម្លៃទៅលើសកម្មភាពបញ្ជ្រាបការយល់ដឹងសម្រាប់ប្រជាពលរដ្ឋក្នុងតំបន់ពីកិច្ចការពារបរិស្ថាន និងភាពស្អាត និងវិធីសាស្ត្រនៃការបញ្ជ្រាប (យុទ្ធនាការសាធារណៈ ព្រឹត្តិការណ៍ ការប្រឡងប្រណាំងជាដើម)។ វាសំដៅផងដែរទៅរកមធ្យោបាយដែលគេប្រើសម្រាប់បញ្ជ្រាបការយល់ដឹងដូចជាកូនសៀវភៅបញ្ជ្រាបការយល់ដឹង បណ្តុះផ្គត់ បដផ្សព្វផ្សាយជាដើម។

### ៥.៤.២. សូចនាករស្តីពីការបញ្ជ្រាបការយល់ដឹងស្តីពីកិច្ចការពារបរិស្ថាន និងភាពស្អាតដល់ប្រតិបត្តិករទេសចរណ៍

ដូចបានរៀបរាប់យ៉ាងច្រើនពីខាងលើ សូចនាករលម្អិតនេះនឹងវាយតម្លៃទៅលើសកម្មភាពបញ្ជ្រាបការយល់ដឹងសម្រាប់ប្រតិបត្តិករទេសចរណ៍ពីកិច្ចការពារបរិស្ថាន និងភាពស្អាត និងវិធីសាស្ត្រនៃការបញ្ជ្រាប (យុទ្ធនាការសាធារណៈ ព្រឹត្តិការណ៍ ការប្រឡងប្រណាំងជាដើម)។ វាសំដៅផងដែរទៅដល់មធ្យោបាយដែលគេប្រើសម្រាប់បញ្ជ្រាបការយល់ដឹងដូចជាកូនសៀវភៅបញ្ជ្រាប បណ្តុះផ្គត់ បដាផ្សព្វផ្សាយជាដើម។

### ៥.៤.៣. សូចនាករស្តីពីការបញ្ជ្រាបការយល់ដឹងអំពីការការពារបរិស្ថាន និងភាពស្អាតដល់ភ្ញៀវទេសចរ

សូចនាករលម្អិតនេះវាយតម្លៃពីកម្រិតនៃការផ្តល់ព័ត៌មានទៅដលភ្ញៀវទេសចរពីការគោរពតាមបទបញ្ញត្តិស្តីពីភាពស្អាត និងបរិស្ថានរបស់ប្រទេសដែលធ្វើឡើងដោយភ្នាក់ងាររដ្ឋ និងអាជីវកម្មឯកជនតាមរយៈការទំនាក់ទំនងជាមួយភ្ញៀវទេសចរ។

## ៥.៥. សូចនាករស្តីពីតំបន់បៃតង

តំបន់បៃតងនៅក្នុងទីក្រុងគឺជាទីកន្លែងសម្រាប់សាធារណជន (ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ) អាចជួបជុំសម្រាកលំហែបាន។ តំបន់នោះមានរៀបចំដាំលម្អដោយផ្កា ដើមឈើ ឬស្មៅជាដើម។

រង្វង់មូលមិនត្រូវបានរាប់បញ្ចូលជាតំបន់បៃតងនោះទេ ពីព្រោះរង្វង់មូលគ្រាន់តែជាចំណែកមួយនៃផ្លូវសាធារណៈ មិនមែនសម្រាប់លំហែកំសាន្តនោះទេ។ តំបន់បៃតងគួរតែត្រូវចែកឲ្យដាច់ចេញពី **"រមណីយដ្ឋានទេសចរណ៍ធម្មជាតិ"** បើទោះជាតំបន់រមណីយដ្ឋានទេសចរណ៍ធម្មជាតិនោះអាចនឹងមានព័ទ្ធដោយតំបន់បៃតងក៏ដោយ។ បន្ថែមពីនេះ ទីក្រុងមិនអាចគិតលុយពីភ្ញៀវទេសចរដែលទៅកំសាន្តនៅក្នុងតំបន់បៃតងដូចរមណីយដ្ឋានទេសចរណ៍មួយចំនួននោះទេ។

តំបន់បៃតងចូលរួមធ្វើឲ្យការរស់នៅរបស់ប្រជាជន មានភាពកាន់តែប្រសើរតាមរយៈការផ្តល់នូវទីកន្លែងធម្មជាតិនៅក្នុងតំបន់ទីក្រុង។ ជាទូទៅ តំបន់បៃតងត្រូវបានគិតគូររៀបចំឲ្យមានមួយចំនួនរួចទៅហើយនៅតាមទីក្រុងនានា។ បន្ថែមលើនេះ ស្តង់ដានេះមានបំណងចូលរួមជម្រុញបន្ថែមលើការប្រើប្រាស់តំបន់បៃតងនេះដោយផ្តោតជាសំខាន់លើការបង្កើនទំហំរបស់តំបន់បៃតង និងការយកចិត្តទុកដាក់ថែទាំពួកវា។
ស្តង់ដានេះទាមទាឲ្យទីក្រុងទាំងអស់រៀបចំតំបន់បៃតងរបស់ខ្លួនដោយគិតគូរពីការថែទាំ និងគ្រងប់គ្រងតាមវិធីសាមញ្ញ និងងាយស្រួលមួយប្រកបដោយជោគជ័យ។

### ៥.៥.១. ទំហំតំបន់បៃតងនៅក្នុងទីក្រុង

សូចនាករលម្អិតនេះវាយតម្លៃទំហំតំបន់បៃតងធៀបទៅនឹងផ្ទៃក្រឡាទីក្រុងទាំងមូល។

### ៥.៥.២. សូចនាករស្តីពីការថែទាំ និងគ្រប់គ្រងតំបន់បៃតង

សូចនាករលម្អិតវាយតម្លៃលើភាពញឹកញាប់នៃការថែទាំតំបន់បៃតង តើមានរៀបចំកម្មវិធីថែទាំតំបន់ឲ្យប្រសើរឬទេ ទំហំ និងការថែទាំសម្ភារៈបរិក្ខាសាធារណៈ (អំពូលភ្លើង កៅអីវែងសម្រាប់អង្គុយ ផ្លូវដើរជាដើម) និងប្រព័ន្ធគ្រប់គ្រងបរិស្ថានដែលមានស្រាប់ (ប្រព័ន្ធសន្សំសំចៃថាមពលសម្រាប់អំពូល ប្រព័ន្ធធារាសាស្ត្រ ការប្រើប្រាស់ជីសរីរាង្គ-ល-)។

## ៥.៦. សូចនាករស្តីពីសុវត្ថិភាពសុខាភិបាល សុវត្ថិភាព និងសន្តិសុខ ទីក្រុង

**សុវត្ថិភាព** គឺជាកត្តាគន្លឹះជាយុទ្ធសាស្ត្រសម្រាប់គោលនយោបាយទេសចរណ៍។ សុវត្ថិភាពត្រូវបានបែងចែកទៅតាមស្ថានភាពគ្មានហានិភ័យ ឬក៏មានហានិភ័យតិចតួច។ **សុវត្ថិភាព** ត្រូវបានចាត់ទុកជាសិទ្ធមនុស្សជាមូលដ្ឋាន។

ការគិតគូរពីសន្តិសុខសុវត្ថិភាពគឺជាកាតព្វកិច្ចរបស់អាជ្ញាធរមូលដ្ឋាន និងការធានាសុវត្ថិភាពរបស់ភ្ញៀវទេសចរ ក៏ដូចជាប្រជាពលរដ្ឋមូលដ្ឋានជាកម្មវត្ថុនៃសូចនាករនេះ។ សូចនាករនេះមានគោលបំណងបង្កើតឲ្យមាននូវភាពសុខដុមនីយកម្មរវាងភ្ញៀវទេសចរអន្តរជាតិ និងប្រជាពលរដ្ឋមូលដ្ឋាន និងមានបំណងជម្រុញទីក្រុងទាំងអស់ចាត់វិធានការផ្សេងៗចូលរួមកាត់បន្ថយរាល់ហានិភ័យដែលនឹងកើតមានគ្រប់រូបភាព និងក្នុងស្មារតីចូលរួមការអភិវឌ្ឍទេសចរណ៍នៅក្នុងបរិបទសុវត្ថិភាពទេសចរណ៍។

សូចនាករនេះវាយតម្លៃទៅលើចំនួន និងគុណភាពនៃមជ្ឈមណ្ឌលសុខាភិបាល ឱសថស្ថាន និងអ្នកផ្គត់ផ្គង់សេវាសុខាភិបាលដែលមានស្រាប់នៅក្នុងទីក្រុង ក៏ដូចជាវាយតម្លៃលើយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យនានា

នៅនឹងកន្លែង ទំហំនៃវិធានការត្រួតពិនិត្យអនាម័យចំណីអាហារ ការគ្រប់គ្រងរបៀបរៀបរយសាធារណៈ សុវត្ថិភាពធ្វើដំណើរនៅជុំវិញទីក្រុង និងការផ្សព្វផ្សាយព័ត៌មានទៅដល់ភ្ញៀវទេសចរ និងប្រជាពលរដ្ឋមូលដ្ឋានអំពីការទប់ស្កាត់ឧក្រិដ្ឋកម្ម និងការជម្រុញអនុវត្តច្បាប់។

### ៥.៦.១. សុវត្ថិភាពសុខាភិបាល

សូចនាករលម្អិតនេះត្រូវវាយតម្លៃដោយផ្អែកលើ ០២ចំណុចៈ ១)ការវាយតម្លៃពីចំនួន និងគុណភាពមជ្ឈមណ្ឌលសុខាភិបាល (មន្ទីរពេទ្យ គ្លីនិក...) និងឱសថស្ថានព្រមទាំងអ្នកផ្តល់សេវាសុខាភិបាលនានា និង ២) ទំហំនៃវិធានការត្រួតពិនិត្យអនាម័យចំណីអាហារនៅទីកន្លែងដែលភ្ញៀវទេសចរប្រមូលផ្តុំ (ភោជនីយដ្ឋាន ទីផ្សារ ហាងលក់អាហារសម្រន់ អ្នកលក់ដូរចល័តជាដើម) យោងតាមច្បាប់ និងបទបញ្ញត្តិដែលមាននៅក្នុងទីក្រុង។

### ៥.៦.២.សុវត្ថិភាព និងសន្តិសុខនៅក្នុងទីក្រុង

សូចនាករលម្អិតនេះនឹងវាយតម្លៃកម្រិតនៃរបៀបរៀបរយនៅនឹងកន្លែង និងវាស់វែងលើចំនួនមន្ត្រីនគរបាល (ពិសេសមន្ត្រីនគរបាលទេសចរណ៍) និងរបៀបដែលពួកគាត់ទទួលបានការហ្វឹកហាត់ដើម្បីដោះស្រាយបញ្ហាទេសចរណ៍។ សូចនាករលំអិតនេះក៏ចាត់បញ្ចូលពីរបៀបដែលអ្នកបើកបរតាក់ស៊ីផ្តល់សេវាទៅដល់ភ្ញៀវទេសចរប្រកបដោយការគួរសម និងស្មោះត្រង់។ សូចនាករបន្ថែមមួយទៀតសំដៅលើសុវត្ថិភាពធ្វើដំណើជុំវិញទីក្រុង (ចរាចរណ៍ ការកកស្ទះ សុវត្ថិភាពផ្លូវឆ្លងកាត់ សុវត្ថិភាពផ្លូវថ្មើរជើង...)។

### ៥.៦.៣. ការទប់ស្កាត់បទឧក្រិដ្ឋ និងជម្រុញការអនុវត្តច្បាប់ (ពេស្យាចារកុមារ គ្រឿងញៀនជាដើម)

សូចនាករនេះធ្វើឲ្យប្រាកដថាមានកិច្ចខំប្រឹងប្រែងនានាដើម្បីការពារប្រជាពលរដ្ឋមូលដ្ឋានចេញពីសកម្មភាពខុសច្បាប់ និងដើម្បីទប់ស្កាត់ភ្ញៀវទេសចរចេញពីការប្រព្រឹត្តិនូវសកម្មភាពដូចជា ពេស្យាចារកុមារ គ្រឿងញៀន ការជួញដូរមនុស្ស ការរត់គេចពន្ធទំនិញ ការបំផ្លាញធនធានបរិស្ថានសម្បត្តិវប្បធម៌ជាដើម។ សូចនាការលំអិតនេះវាយតម្លៃពីការពង្រឹងការអនុវត្តច្បាប់នេះ (ដែលរួមមានការយាមល្បាតនិងការដាក់ទណ្ឌកម្ម) និងប្រសិទ្ធភាពនៃយុទ្ធនាការលើកកំពស់ការយល់ដឹងផងដែរ។

### ៥.៦.៤. យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ

សូចនាករលំអិតនេះវាយតម្លៃពីសមត្ថភាពរបស់ប្រទេសក្នុងការដោះស្រាយជាមួយហេតុការណ៍ដែលមិនបានរំពឹងទុក ដូចជាគ្រោះធម្មជាតិ ជាដើម។ វាវាយតម្លៃពីវិសាលភាព និងប្រសិទ្ធភាពនៃយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យប្រសិនបើវាមាន។

## ៥.៧. សូចនាករនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទ្រទ្រង់ទេសចរណ៍

ហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទ្រទ្រង់ទេសចរណ៍ គឺជាសមាសធាតុដ៏សំខាន់សម្រាប់គោលនយោបាយអភិវឌ្ឍន៍វិស័យទេសចរណ៍។ ការអភិវឌ្ឍវិស័យទេសចរណ៍គឺត្រូវពឹងផ្អែកលើហេដ្ឋារចនាសម្ព័ន្ធ ការតភ្ជាប់ និងភាពសំបូរបែបនៃសម្បទាទ្រទ្រង់ទាំងនេះ។ វាគឺពិតប្រាកដណាស់ថា ភាពសម្បូរបែបនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទ្រទ្រង់ទាំងនេះនឹងជួយសម្រួលដល់ការធ្វើដំណើរ និងការដឹកជញ្ជូនដែលមានសារៈសំខាន់ចាំបាច់សម្រាប់

វិស័យទេសចរណ៍។ ប្រសិនបើអ្វីមួយដែលត្រូវបានរៀបរាប់ខាងក្រោមនេះ មានការខ្វះខាត ឬមានការរំខាន ដោយហេតុផលណាមួយ នោះវានឹងបង្ករឲ្យមានការរាំងស្ទះក្នុងការអភិវឌ្ឍទីក្រុង ក៏ដូចជាកំណើននៃទេសចរណ៍ទីក្រុង។ អ្វីដែលសំខាន់បំផុតនោះគឺថាបណ្ដាទីក្រុងនានាត្រូវមានផែនការត្រឹមត្រូវសម្រាប់វិស័យទេសចរណ៍ ដោយមានការចង្អុលបង្ហាញពីផែនការ និងយុទ្ធសាស្រ្តដើម្បីពិនិត្យមើលចង្វាក់នៃការអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងទីក្រុង។ ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់គឺផ្ដោតសំខាន់ទៅលើមជ្ឈមណ្ឌលផ្ដល់ព័ត៌មាន ស្លាកសញ្ញាសំគាល់តំបន់គោលដៅទេសចរណ៍ និងផែនទីទេសចរណ៍ដែលមានសារៈសំខាន់ណាស់សម្រាប់ការផ្ដល់សេវាកម្មទេសចរណ៍នៅក្នុងទីក្រុង។ ទីកន្លែងផ្សេងទៀតដែលភ្ញៀវទេសចរ ព្រមទាំងប្រជាជនក្នុងតំបន់អាចរីករាយរួមគ្នាជាមួយនឹងឧបករណ៍សម្រាប់បម្រើគោលបំណងផ្សេងគ្នា ដូចជាការសំរាកលំហែ វប្បធម៌ ការសិក្សា ការដើរទិញឥវ៉ាន់ កីឡា-ល- នឹងត្រូវបានផ្ដល់ជាអនុសាសន៍នៅក្នុងទីក្រុង។

ការពេញចិត្តរបស់ភ្ញៀវទេសចរត្រូវបានរួមបញ្ចូលនៅក្នុងសូចនាករនេះ ដូចជាបណ្ដាទីក្រុងនានាត្រូវតែមានការយល់ដឹងពីអ្វីដែលត្រូវធ្វើឱ្យប្រសើរឡើងក្នុងគោលបំណងដើម្បីទាក់ទាញភ្ញៀវទេសចរនិងលើកទឹកចិត្តពួកគេឱ្យស្នាក់នៅបានយូរនៅក្នុងទីក្រុង។

**៥.៧.១. ផែនការសម្រាប់វិស័យទេសចរណ៍**

សូចនាករលំអិតនេះពិនិត្យមើលថាតើផែនការ និងយុទ្ធសាស្រ្តផ្លូវការគឺត្រូវបានរៀបចំដើម្បីត្រួតពិនិត្យការអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងទីក្រុង ដូចជាផែនការតំបន់ និងគម្រោងប្រើប្រាស់ដីសម្រាប់តំបន់ទេសចរណ៍ ផ្លូវដែលបានគ្រោងទុកសម្រាប់ភ្ញៀវទេសចរ គ្រោងសម្រាប់ការដឹកជញ្ជូនភ្ញៀវទេសចរ និងផែនការការពារវប្បធម៌និងបេតិកភណ្ឌ-ល- ។

**៥.៧.២. មជ្ឈមណ្ឌលផ្ដល់ព័ត៌មាន ស្លាកសញ្ញា និងផែនទីទេសចរណ៍**

សូចនាករលំអិតនេះវាយតម្លៃពីវិធីសាស្រ្ត និងប្រសិទ្ធិភាពនៃការផ្ដល់សេវាកម្មទេសចរណ៍នៅក្នុងទីក្រុង ដូចជា ទំហំ និងទីតាំងនៃមជ្ឈមណ្ឌលព័ត៌មាន និងគុណភាពនៃសម្ភារៈដែលអាចប្រើប្រាស់ ស្លាកសញ្ញាសំគាល់តំបន់គោលដៅទេសចរនៅជុំវិញទីក្រុង និងថាតើផែនទីទេសចរណ៍មានមាតិកាដែលផ្ដោតលើទីតាំងដែលជាការចាប់អារម្មណ៍នៅក្នុងទីក្រុង។

**៥.៧.៣.ទីតាំងនៃមជ្ឈមណ្ឌលលក់ឥវ៉ាន់ និងហាងលក់រាយ**

សូចនាករលំអិតនេះវាយតម្លៃពីទីកន្លែងដែលភ្ញៀវទេសចរអាចរកឃើញនូវអ្វីដែលជាចំនុចចាប់អារម្មណ៍ ថាតើវាគឺជាតំបន់ទេសចរណ៍ដែលនៅជិត និងនៅកណ្ដាលទីក្រុង ភាពងាយស្រួលនៃការធ្វើដំណើរចេញចូល និងគុណភាព និងតម្លៃនៃវត្ថុសិប្បកម្មនិងវត្ថុអនុស្សាវរីយ៍ក្នុងស្រុក ។

**៥.៧.៤. តំបន់សម្រាកលំហែ (តំបន់ទេសចរណ៍ ឧទ្យានសាធារណៈ កីឡា និងការកំសាន្ត ... )**

សូចនាករលំអិតនេះវាយតម្លៃមិនត្រឹមតែបណ្ដុំនៃសកម្មភាពដែលភ្ញៀវទេសចរអាចរកបានប៉ុណ្ណោះទេ តែថែមទាំងធានាថាសកម្មភាពទាំងនេះគឺអាចផ្ដល់ផលប្រយោជន៍ដល់ប្រជាជនក្នុងតំបន់ផងដែរ។

**៥.៧.៥. កម្រិតនៃពេញចិត្តរបស់ភ្ញៀវទេសចរ**

សូចនាករលំអិតមានសារៈសំខាន់ក្នុងការត្រួតពិនិត្យថាតើចំនួនភ្ញៀវទេសចរប៉ុន្មាននាក់ដែលទទួលបានភាពរីករាយ និងមានការពេញចិត្តនៅក្នុងទីក្រុង(ភាពស្អាត ការស្វាគមន៍និងបដិសណ្ឋារកិច្ច សន្តិ

សុខ ការកោតសរសើរនៃការតុបតែង និងបរិស្ថាន ជាដើម ... ) និងដើម្បីកំណត់ថាកន្លែងដែលត្រូវធ្វើឲ្យមានភាពប្រសើរឡើងថែមទៀត។ ការធ្វើការស្ទង់មតិជាប្រចាំគឺមានសារៈសំខាន់ខ្លាំងណាស់ដើម្បីវាស់ស្ទង់ព័ត៌មាន ហើយវាត្រូវបានធ្វើការវិភាគ។ សូចនាករនេះវាយតម្លៃថាតើការស្ទង់មតិទាំងនេះត្រូវបានអនុវត្ត ញឹកញាប់កម្រិតណា ហើយសកម្មភាពទាំងនោះត្រូវបានធ្វើដើម្បីកែលម្អទីក្រុងនេះដោយផ្អែកទៅលើទិន្នន័យដែលទទួលបានពីការស្ទង់មតិនេះដែរឬទេ។

## ៦. ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន-លក្ខណៈវិនិច្ឆ័យ

### ៦.១. តារាងវាយតម្លៃលើសូចនាករចំនួន០៥ នៃការគ្រប់គ្រងបរិស្ថាន

| ការគ្រប់គ្រងបរិស្ថាន | | លក្ខណៈវិនិច្ឆ័យ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|---|
| ១ | ផែនការរៀបចំទីក្រុង | តើមានផែនការមេនៃការប្រើប្រាស់ដីសម្រាប់ទីក្រុង? | មាន<br>មិនមាន | ☐<br>☐ |
| | | តើបានប្រតិបត្តិទៅតាមផែនការមេនោះដែរឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើទីក្រុងត្រូវបានបែងចែកច្បាស់លាស់ទៅតាមផែនការបែងចែកតំបន់ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានផែនការរៀបចំការធ្វើដំណើរសម្រាប់ទីក្រុងដែរ ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើទិដ្ឋភាពបរិស្ថានត្រូវបានបញ្ចូលក្នុងផែនការឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើទិដ្ឋភាពបរិស្ថានទាំងនេះត្រូវបានអនុវត្ត ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| ២ | បទបញ្ញត្តិស្តីពីបរិស្ថាន | តើបទបញ្ញត្តិស្តីពីបរិស្ថានអាចត្រួតពិនិត្យលើដំណើរប្រតិបត្តិការនៃអាជីវកម្មទេសចរណ៍ដែរឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើទាំងនេះត្រូវបានប្រតិបត្តិក្នុងទីក្រុង ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| ៣ | ការបំពុល | តើបទដ្ឋានគុណភាពទឹកត្រូវបានរៀបចំដោយអាជ្ញាធរឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើទាំងនេះត្រូវបានអនុវត្តក្នុងទីក្រុង ឬទេ? | មាន<br>មិនមាន | ☐<br>☐ |

| | | | | |
|---|---|---|---|---|
| | | តើគុណភាពទឹកក្នុងទីក្រុងស្ថិតក្នុងបទដ្ឋានដែលបាន កំណត់ ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើបទដ្ឋានគុណភាពខ្យល់ត្រូវបានកំណត់ដោយ អាជ្ញាធរក្នុងទីក្រុងដែរឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើទាំងនេះត្រូវបានអនុវត្តក្នុងទីក្រុង ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើគុណភាពខ្យល់ និងគុណភាពទឹកត្រូវបាន ប្រកាសផ្សព្វផ្សាយជាសាធារណៈ ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើអាជ្ញាធរមានរៀបចំនូវវិធានការ ដើម្បីកាត់បន្ថយ ការបំពុលបរិស្ថានខ្យល់ដែរឬទេ? ដូចជាគំនិតផ្តួចផ្តើម កាត់បន្ថយការស្ទះចរាចរណ៍ ឧទាហរណ៍៖ បំលែង ការប្រើប្រាស់ប្រេង | មាន<br>មិនមាន | ☐<br>☐ |
| | | តើទាំងនេះត្រូវបានអនុវត្តក្នុងទីក្រុង ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើអាជ្ញាធរមានរៀបចំណែនាំវិធានការ ដើម្បីកាត់ បន្ថយ ការបំពុលបរិស្ថានសម្លេងដែរឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើទាំងនេះត្រូវបានប្រតិបត្តិក្នុងទីក្រុង | មាន<br>មិនមាន | ☐<br>☐ |
| ៤ | **មធ្យោបាយធ្វើដំណើរដែលគិតគូរពីបរិស្ថាន** | តើមានប្រព័ន្ធដឹកជញ្ជូនសាធារណៈក្នុងទីក្រុង ដែរឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើអាជ្ញាធរបានណែនាំអំពីការធ្វើដំណើរជាសាធារណៈដែលគិតគូរដល់បរិស្ថានដែរឬទេ? (យន្តការត្រួតពិនិត្យការបំពុល) | មាន<br>មិនមាន | ☐<br>☐ |
| | | តើអាជ្ញាធរបានដាក់ចេញនូវបទបញ្ជាដើម្បីត្រួតពិនិត្យការបំពុលបរិស្ថានបង្កឡើងដោយចរាចរណ៍ ឬទេ? (ដូចជាការហាមឃាត់រថយន្ត ដែលបញ្ចេញសារធាតុពុលច្រើន ការផាកពិន័យលើការកកស្ទះចរាចរណ៍ ក្នុងទីក្រុង...) | មាន<br>មិនមាន | ☐<br>☐ |
| | | តើទាំងនេះត្រូវបានអនុវត្តក្នុងទីក្រុង ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានសមាមាត្រនៃការប្រើប្រាស់យានយន្តដែល | ភាគរយតិច | |

| | | | | |
|---|---|---|---|---|
| | | គិតគូរដល់បរិស្ថាន និងយានជំនិះមិនប្រើប្រេងឥន្ទនៈធៀបទៅនឹងចំនួនយានជំនិះទាំងអស់ដែលមានប៉ុន្មានភាគរយ? | បំផុត៣០%នៃចំនួនសរុបដើម្បីទទួលបាន១ពិន្ទុ | |
| | | តើអាជ្ញាធរបានលើកទឹកចិត្តប្រជាជន(ក្នុងស្រុក) ឲ្យប្រើប្រាស់មធ្យោបាយដឹកជញ្ជូនមិនប្រើឥន្ទនៈ ការជិះកង់ ឬ ការដើរដែរ ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| ៥ | ការប្រើប្រាស់ថាមពលប្រកបដោយនិរន្តរភាព | តើមានសមមាត្រសណ្ឋាគារក្នុងទីក្រុងដែលប្រើប្រាស់ឧបករណ៍សន្សំសំចៃអគ្គីសនី និងថាមពលកកើតឡើងវិញ? | តិចជាង ៥0%<br>រហូតដល់ ឬច្រើនជាង ៥0%<br>(តិចបំផុត៥0%ដើម្បីទទួលបាន១ពិន្ទុ) | ☐<br>☐ |
| | | តើមានសមាមាត្រនៃភោជនីយដ្ឋានក្នុងទីក្រុងដែលប្រើប្រាស់ឧបករណ៍សន្សំសំចៃអគ្គីសនី និងថាមពលកកើតឡើងវិញប៉ុន្មានភាគរយ? | តិចជាង ៥0%<br>រហូតដល់ ឬច្រើនជាង ៥0%<br>(តិចបំផុត៥0%ដើម្បីទទួលបាន១ពិន្ទុ) | ☐<br>☐ |
| | | តើអាជីវកម្មទេសចរណ៍បានជ្រួតជ្រាប និងអាចប្រើប្រាស់បច្ចេកទេសសន្សំសំចៃថាមពលតាមរយៈយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងនេះ ឬទេប៉ុន្មានភាគរយ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានវិធានការលើកទឹកចិត្តសម្រាប់ការប្រើប្រាស់ថាមពលប្រកបដោយនិរន្តភាពឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| - **ចំនួននៃសូចនករលំអិតៈ ៥**<br>- **ចំនួននៃលក្ខណៈវិនិច្ឆ័យៈ ២៨** | | | **សរុប** | **២៨** |

**៦.២. តារាងវាយតម្លៃលើសូចនាករចំនួន០៤ នៃភាពស្អាត**

| **ការគ្រប់គ្រងបរិស្ថាន** | | **លក្ខណៈវិនិច្ឆ័យ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|---|
| | **ភាពស្អាតនៅតាមទីកន្លែងសាធារណៈ** | តើអាជ្ញាធរក្រុងបានធ្វើការសម្អាតទីសាធារណៈញឹកញាប់កម្រិតណា? | ១ថ្ងៃម្តង ឬញឹកញាប់ជាង (តិចបំផុត១ថ្ងៃម្តងដើម្បីទទួលបាន១ពិន្ទុ)<br>តិចជាងម្តងក្នុង១ថ្ងៃ | ☐<br>☐ |

| | | | | |
|---|---|---|---|---|
| | | តើសំភារៈបរិក្ខារប្រើប្រាស់សាធារណៈ (បង់សាធារណៈ ចំណតឡានក្រុង។ល។) ត្រូវការថែទាំ និងសំអាតជាប្រចាំ ឬទេ? | មាន<br>មិនមាន | |
| | | តើមានធុងសំរាមសាធារណៈគ្រប់គ្រាន់ទេ នៅទីសាធារណៈ? | មាន<br>មិនមាន | |
| | | តើសំរាមទាំងនេះត្រូវបានប្រមូលសំរាមជាប្រចាំ ឬទេ? | មាន<br>មិនមាន | |
| | | តើអាគារសាធារណៈត្រូវបានដាក់ស្លាកសញ្ញាសមរម្យទេ? | មាន<br>មិនមាន | |
| ២ | **ភាពស្អាតនៅតាមបង្គន់សាធារណៈ** | តើបង្គន់សាធារណៈត្រូវបានសំអាត និងថែទាំជាប្រចាំឬទេ? (ភ្ជាប់ទៅនឹងស្តង់ដាបង្គន់សាធារណៈអាស៊ាន) | មាន<br>មិនមាន | |
| | | តើបង្គន់សាធារណៈត្រូវបានលាងសំអាតញឹកញាប់ប៉ុណ្ណា? | ២ដងក្នុងមួយថ្ងៃ ឬញឹកញាប់ជាងនេះ<br>(តិចបំផុត២ដងក្នុងមួយថ្ងៃដើម្បីទទួលបាន១ពិន្ទុ)<br>តិចជាង២ដងក្នុងមួយថ្ងៃ | |
| | | តើមានបែងចែករវាងបង្គន់បុរស និងបង្គន់ស្រី និងបង្គន់សម្រាប់ជនពិការ ឬទេ? | មាន<br>មិនមាន | |
| | | តើបង្គន់សាធារណៈត្រូវបានដាក់ស្លាកសញ្ញាត្រឹមត្រូវដែរ ឬទេ? | មាន<br>មិនមាន | |
| ៣ | **ភាពស្អាតនៅតាមរមណីយដ្ឋានទេសចរណ៍** | តើតំបន់ទេសចរណ៍ត្រូវបានយកចិត្តទុកដាក់ជាពិសេសអំពីការសំអាតជាប្រចាំ ឬទេ? | មាន<br>មិនមាន | |
| | | តើទីកន្លែងទេសចរណ៍ត្រូវបានសម្អាតញឹកញាប់កម្រិតណា? | ២ម្តងក្នុង១ថ្ងៃ ឬញឹកញាប់ជាងនេះ<br>(តិចបំផុត២ម្តងក្នុងមួយថ្ងៃដើម្បីទទួលបាន១ពិន្ទុ)<br>តិចជាង២ដងក្នុង១ថ្ងៃ | |
| | | តើមានធុងសំរាមនៅទីកន្លែងទេសចរណ៍គ្រប់គ្រាន់ឬទេ? | មាន<br>មិនមាន | |
| | | តើមានបង្គន់នៅទីកន្លែងទេសចរណ៍គ្រប់គ្រាន់ឬទេ? | មាន<br>មិនមាន | |

| | | | | |
|---|---|---|---|---|
| | | តើទីកន្លែងទេសចរណ៍ត្រូវបានដាក់ស្លាកសញ្ញាសមរម្យឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| ៤ | ភាពស្អាតនៅតាមបណ្តោយផ្លូវធំ | តើតំបន់ជុំវិញផ្លូវធំក្នុងទីក្រុងត្រូវបានសម្អាតញឹកញាប់ឬទេ? | ២ដងក្នុង១ថ្ងៃ ឬញឹកញាប់ជាង (តិចបំផុត២ដងក្នុងមួយថ្ងៃដើម្បីទទួលបាន១ពិន្ទុ)<br>តិចជាង២ដងក្នុង១ថ្ងៃ | ☐<br>☐ |
| | | តើឧបករណ៍ត្រូវបានប្រើប្រាស់សមរម្យឬទេ? (ចន្លោះពីធុងសំរាមមួយទៅមួយទៀតត្រូវបំពាក់ឲ្យបានស្មើៗគ្នា) | មាន<br>មិនមាន | ☐<br>☐ |
| - **ចំនួននៃសូចនករលំអិតៈ ៤**<br>- **ចំនួននៃលក្ខណៈវិនិច្ឆ័យៈ ១៦** | | | **សរុប** | **១៦** |

## ៣.តារាងវាយតម្លៃលើសូចនាករចំនួន០៥ នៃការគ្រប់គ្រងសំណល់

| ការគ្រប់គ្រងសំណល់ | | លក្ខណៈវិនិច្ឆ័យ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|---|
| ១ | ការប្រមូលសំណល់រាវ | តើមានប្រពន្ធ័ប្រមូលកាកសំណល់រាវក្នុងទីក្រុងឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានបទដ្ឋានពាក់ព័ន្ធ នឹងការប្រមូលកាកសំណល់រាវឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានការដាក់ចេញនូវវិធានការដើម្បីដាក់ទោសការបំពានលើបទដ្ឋាននេះឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | ភាគរយនៃចំនួនប្រជាជនទីក្រុងដែលបានភ្ជាប់ទៅនឹងប្រព័ន្ធលូ? | .........%(តិចបំផុត៧០%នៃចំនួនសរុបដើម្បីទទួលបាន១ពិន្ទុ) | ☐ |
| | | តើសម្បទាទេសចរណ៍ដែលបានភ្ជាប់ទៅនឹងលូមេបង្ហូរទឹកមានប៉ុន្មានភាគរយ? | .........%(តិចបំផុត៧០%នៃចំនួនសរុបដើម្បីទទួលបាន១ពិន្ទុ) | ☐ |

| | | | | |
|---|---|---|---|---|
| | | តើមានមធ្យោបាយបន្ថែមណាដែលបានប្រើដើម្បីបញ្ចេញកាកសំណល់រាវ? | អាងផ្ទុកទឹកសំអុយរួម<br>អាងផ្ទុកទឹកសំអុយឯកជន<br>អណ្តូងស្ងួត(ត្រាំចោលឆ្ងាយ)<br>គ្មានប្រព័ន្ធចាត់ចែងបង្ហូរចោល (គ្មានពិន្ទុ) | ☐<br>☐<br>☐<br>☐ |
| ២ | **គុណភាពនៃការប្រមូលសំណល់រឹង** | តើក្រុងបានប្រមូលកាកសំណល់រឹងឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | បើគ្មាន តើកាកសំណល់រឹងត្រូវប្រមូលដោយរបៀបណា? | ក្រុមហ៊ុនឯកជន<br>NGO (បញ្ជាក់ឲ្យច្បាស់) | ☐<br>☐ |
| | | តើកាកសំណល់រឹងត្រូវបានប្រមូលចោលញឹកញាប់ឬទេ? | មួយថ្ងៃម្តង ឬច្រើនជាងនេះ (តិចបំផុត១ថ្ងៃម្តងដើម្បីទទួលបាន១ពិន្ទុ)<br>តិចជាង១ដងក្នុងមួយថ្ងៃ | ☐<br>☐ |
| | | តើសមាមាត្រប្រជាជនដែលបានភ្ជាប់ទៅនឹងប្រព័ន្ធចាត់ចែងប្រមូលកាកសំណល់រឹងមានប៉ុន្មានភាគរយ? | ..........%(តិចបំផុត៧0%នៃចំនួនសរុបដើម្បីទទួលបាន១ពិន្ទុ | |
| | | តើសម្បទាទេសចរណ៍ដែលបានភ្ជាប់ទៅនឹងប្រព័ន្ធប្រមូលកាកសំណល់មានប៉ុន្មានភាគរយ? | ..........%(តិចបំផុត៧0%នៃចំនួនសរុបដើម្បីទទួលបាន១ពិន្ទុក | |
| ៣ | **ការរក្សាទុកសំណល់រាវ និងការធ្វើប្រព្រឹត្តិកម្ម** | តើមានតំបន់រក្សាទុកកាកសំណល់រាវដែលប្រជាពលរដ្ឋទីក្រុងអាចប្រើប្រាស់បានឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានសម្បទាសម្រាប់រក្សាទុកសំណល់(ដូចជាអាងចម្រោះទឹកសំអុយ)នៅជិតតំបន់ទេសចរណ៍ដែរឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានរោងចក្រធ្វើប្រព្រឹត្តិកម្មនៅជិតទីក្រុងឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| ៤ | **ការរក្សាទុកសំណល់រឹង និងការធ្វើប្រព្រឹត្តិកម្ម** | តើមានតំបន់សម្រាប់ចាក់កាកសំណល់ចោល (ដូចជា កន្លែងចាក់សំរាម រោងចក្រដុតរំលាយ) នៅជិតទីក្រុងឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានរោងចក្រធ្វើប្រព្រឹត្តិកម្មនៅជិតក្រុង | មាន | ☐ |

| | | | | |
|---|---|---|---|---|
| | | ឬទេ? | មិនមាន | ☐ |
| ៥ | **ការប្រើប្រាស់ឡើងវិញ** | តើអាជ្ញាធរក្រុងបានលើកទឹកចិត្តដល់ការប្រើប្រាស់ឡើងវិញ និងប្រមូលកាកសំណល់ពីកន្លែងប្រជាជនឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានប្រព័ន្ធប្រមូលកាកសំណល់ពុល និងកាកសំណល់ប៉ះពាល់បរិស្ថានឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានឧបករណ៍សមរម្យសម្រាប់ធ្វើការកែច្នៃ ឬទេ?(ដូចជាធុងដែលមានការអប់រំបែងចែកសំរាមបីប្រភេទជាដើម) | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានការធ្វើយុទ្ធនាការផ្សព្វផ្សាយបញ្ជ្រាបយល់ដឹងជាប្រចាំឬទេអំពីការប្រើប្រាស់ឡើងវិញសម្រាប់ប្រជាជន និងសហគ្រាសក្នុងវិស័-យទេសចរណ៍? | មាន<br>មិនមាន | ☐<br>☐ |
| - **ចំនួននៃសូចនករលំអិតៈ ៥**<br>- **ចំនួននៃលក្ខណៈវិនិច្ឆ័យៈ ២០** | | | **សរុប** | **២០** |

## ៦.៤. តារាងវាយតម្លៃលើសូចនាករចំនួន០៣ នៃការបញ្ជ្រាបការយល់ដឹងអំពីកិច្ចការពារបរិស្ថាន និង ភាពស្អាត

| **ការបញ្ជ្រាបការយល់ដឹងអំពីកិច្ចការពារបរិស្ថាន និងភាពស្អាត** | | **លក្ខណៈវិនិច្ឆ័យ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|---|
| ១ | **ការបញ្ជ្រាបការយល់ដឹងដល់ប្រជាជនក្នុងស្រុកអំពីការការពារបរិស្ថាន និងភាពស្អាត** | តើមានយុទ្ធនាការការបញ្ជ្រាបការយល់ដឹង (ផ្សព្វផ្សាយសាធារណៈ ព្រឹត្តិការណ៍ផ្សេងៗ កម្មវិធីប្រកួតប្រជែងនានា...)ដល់ប្រជាជនក្នុងស្រុក ស្តីអំពីកិច្ចការពារបរិស្ថាន និងភាពស្អាត ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើញឹកញាប់កម្រិតណា? | ___ពេល<br>(តិចបំផុតមួយឆ្នាំម្តងដើម្បីទទួលបាន១ពិន្ទុ) | |
| | | តើអាជ្ញាធរបានផលិត និងចែកចាយឯកសារ | មាន | ☐ |

| | | | | |
|---|---|---|---|---|
| | | ផ្សព្វផ្សាយសាធារណៈស្ដីអំពីកិច្ចការពារបរិស្ថាន និងភាពស្អាត(កូនសៀវភៅ, ប័ណ្ណផ្ទត់ បដា ប័ណ្ណប្រកាស ឬទេ? | មិនមាន | ☐ |
| ២ | **ការបញ្ជ្រាបការយល់ដឹងដល់ក្រុមហ៊ុនទេសចរណ៍អំពីបរិស្ថាន និងភាពស្អាត** | តើមានយុទ្ធការបញ្ជ្រាបការយល់ដឹង (ផ្សព្វផ្សាយជាសាធារណៈ ព្រឹត្តិការណ៍ប្រកួតប្រជែងដល់បុគ្គលិកនៃសហគ្រាសទេសចរណ៍ស្ដីអំពីការការពារបរិស្ថាននិងភាពស្អាត ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើញឹកញាប់កម្រិតណា? | ___ពេល<br>(តិចបំផុតមួយឆ្នាំម្ដងដើម្បីទទួលបាន១ពិន្ទុ) | |
| | | តើមានឧបករណ៍ និងសកម្មភាពសមរម្យសម្រាប់គោលបំណងនេះ ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| ៣ | **ការបញ្ជ្រាបការយល់ដឹងដល់ទេសចរអំពីកិច្ចការពារបរិស្ថាន និងភាពស្អាត** | តើទេសចរបានយល់ដឹងអំពីកិច្ចខិតខំរបស់អាជ្ញាធរក្រុងលើកិច្ចការពារបរិស្ថាននិងភាពស្អាត និងបទបញ្ញត្តិ ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើញឹកញាប់កម្រិតណា? | ___ពេល<br>(តិចបំផុតមួយឆ្នាំម្ដងដើម្បីទទួលបាន១ពិន្ទុ | |
| | | តើមានសម្ភារៈ និងសកម្មភាព សមរម្យឬទេសម្រាប់គោលបំណងនេះ ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| - **ចំនួននៃសូចនករលំអិត៖ ៣**<br>- **ចំនួននៃលក្ខណៈវិនិច្ឆ័យ៖៩** | | | **សរុប** | **៩** |

## ៦.៥. តារាងវាយតម្លៃលើសូចនាករចំនួន០២ នៃតំបន់បៃតង

| **តំបន់បៃតង** | | **លក្ខណៈវិនិច្ឆ័យ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|---|
| ១ | **ទំហំតំបន់បៃតងក្នុងទីក្រុង** | តើមានសួនច្បារប៉ុន្មានក្នុងទីក្រុង? | ___(ចំនួន)<br>(តិចបំផុតមួយឆ្នាំម្ដង ដើម្បីទទួលបាន១ពិន្ទុ) | |
| | | តើសមាមាត្រនៃតំបន់បៃតងមានប៉ុន្មានភាគរយ | ___% | |

| | | | | |
|---|---|---|---|---|
| | | ធៀបទៅនឹងផ្ទៃដីសរុបដែលមានក្នុងទីក្រុង? | (តិចបំផុតមួយ៥%ដើម្បីទទួលបាន១ពិន្ទុ) | |
| ២ | **ការថែទាំ និងគ្រប់គ្រងតំបន់បៃតង** | តើស្ថាប័នណាមួយដែលទទួលបន្ទុកថែទាំ និងគ្រប់គ្រងតំបន់បៃតង? | អាជ្ញាធរសាធារណៈ<br>ក្រុមហ៊ុនឯកជន<br>ផ្សេងៗ(ដូចជាNGO)(បញ្ជាក់ឲ្យច្បាស់)<br>គ្មាន(គ្មានពិន្ទុ) | ☐<br>☐<br>☐<br>☐ |
| | | តើមានការថែទាំ និងកម្មវិធីគ្រប់គ្រងជាប្រចាំតាមតារាងពេលវេលាឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានប្រព័ន្ធគ្រប់គ្រងបរិស្ថានកំពុងដំណើរការឬទេ? (ប្រព័ន្ធសន្សំសំចៃថាមពលសម្រាប់ការបំភ្លឺជាដើម ប្រព័ន្ធធារាសាស្ត្រការប្រើប្រាស់ដីសវីរាង្គ) | មាន<br>មិនមាន | ☐<br>☐ |
| - **ចំនួននៃសូចនករលំអិត៖ ២**<br>- **ចំនួននៃលក្ខណៈវិនិច្ឆ័យ៖៥** | | | **សរុប** | **៥** |

## ៦.៦. តារាងវាយតម្លៃលើសូចនាករចំនួន០៤ នៃសុវត្ថិភាពសុខាភិបាល សុវត្ថិភាព និង សន្តិសុខទីក្រុង

| **សុវត្ថិភាពសុខាភិបាល និងសន្តិសុខ និងសុវត្ថិភាពទីក្រុង** | | **លក្ខណៈវិនិច្ឆ័យ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|---|
| ១ | សុវត្ថិភាពសុខាភិបាល | តើមានមណ្ឌលសុខភាពគ្រប់គ្រាន់ក្នុងទីក្រុងដែរឬទេ? | មាន (តិចបំផុតមានមួយសម្រាប់អ្នកស្រុក៥០០នាក់ដើម្បីទទួលបាន១ពិន្ទុ)<br>ទេ | ☐<br>☐ |
| | | តើមានឱសថស្ថានក្នុងទីក្រុងគ្រប់គ្រាន់ដែរឬទេ? | មាន(តិចបំផុតមានមួយសម្រាប់អ្នកស្រុក៥០០នាក់ដើម្បីទទួលបាន១ពិន្ទុ<br>ទេ | ☐<br>☐ |

| | | | | |
|---|---|---|---|---|
| | | តើមានបទដ្ឋានអនាម័យសម្រាប់កន្លែងដែលទេសចរប្រមូលផ្តុំ ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានការធ្វើអធិការកិច្ចអំពីអនាម័យជាញឹកញាប់នៅកន្លែងដែលទេសចរប្រមូលផ្តុំ (ដូចជា៖ ភោជនីយដ្ឋាន ផ្សារ ហាងធ្វើនិងលក់ម្ហូបរហ័ស អ្នកលក់តាមផ្លូវ?) | រៀងរាល់ខែ ឬច្រើនជាងនេះ (តិចបំផុតមួយខែម្តង ដើម្បីទទួលបាន១ពិន្ទុ)<br>តិចជាង១ដងក្នុង១ខែ | ☐<br>☐ |
| **២** | **សុវត្ថិភាព និងសន្តិសុខទីក្រុង** | តើមានមន្ត្រីនគរបាលក្នុងទីក្រុងគ្រប់គ្រាន់ ឬទេ?(ផ្អែកលើបទដ្ឋានប្រទេសរៀងខ្លួន) | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានអង្គភាពនគរបាលទេសចរណ៍ក្នុងទីក្រុង ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើពួកគេត្រូវបានបណ្តុះបណ្តាលសមរម្យឬទេដើម្បីដោះស្រាយបញ្ហាដែលអាចកើតឡើងសម្រាប់ភ្ញៀវទេសចរ? | មាន<br>មិនមាន | ☐<br>☐ |
| **៣** | **ការទប់ស្កាត់បទឧក្រិដ្ឋ និងជម្រុញការអនុវត្តច្បាប់** | តើមានបទបញ្ញាវិធានការបង្ការ និងការពារ និងសកម្មភាពប្រឆាំងនឹងសកម្មភាពខុសច្បាប់ដែលបណ្តាលមកពីប្រតិបត្តិការក្នុងវិស័យទេសចរណ៍ ដើម្បីការពារប្រជាជនក្នុងស្រុក(ដូចជា៖ ពេស្យាចារកុមារ ថ្នាំញៀន ជួញដូរលួចលាក់ វត្ថុពន្ធខុសច្បាប់ ការខូចខាតដល់បរិស្ថាននិងសម្បត្តិវប្បធម៌..)? | មាន<br>មិនមាន | ☐<br>☐ |
| | | តើយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងដើម្បីបញ្ចុះបញ្ចូលទេសចរមិនឲ្យប្រព្រឹត្តអំពើខុសច្បាប់បានជាប្រចាំឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| **៤** | **យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ** | តើបានរៀបចំឲ្យមានប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើបានធ្វើបច្ចុប្បន្នភាពជាប្រចាំ ឬទេហើយអ្នកសំខាន់ៗបានចូលរួមបណ្តុះបណ្តាល និងជំនាញរបស់ពួកគេ ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើបានរៀបចំឲ្យមានប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| **-ចំនួននៃសូចនករលំអិត៖៤**<br>**-ចំនួនលក្ខណៈវិនិច្ឆ័យ៖១២** | | | **សរុប** | **១២** |

## ៧.៧. តារាងវាយតម្លៃលើសូចនាករចំនួន០៥ នៃហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារទ្រទ្រង់ទេសចរណ៍

| ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារទ្រទ្រង់ទេសចរណ៍ | | លក្ខណៈវិនិច្ឆ័យ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|---|
| ១ | ផែនការសម្រាប់វិស័យទេសចរណ៍ | តើមានផែនការមេអភិវឌ្ឍន៏វិស័យទេសចរណ៍សម្រាប់ទីក្រុងដែរ ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើផែនការមេត្រូវបានអនុវត្ត? | មាន<br>មិនមាន | ☐<br>☐ |
| | | តើផែនការមេត្រូវបានត្រួតពិនិត្យ និងកែតម្រូវជាប្រចាំ (តិចបំផុតពីរឆ្នាំម្តង)? | មាន<br>មិនមាន | ☐<br>☐ |
| ២ | មណ្ឌលផ្តល់ព័ត៌មាន ស្លាកសញ្ញា និងផែនទីទេសចរណ៍ | តើមានមណ្ឌលព័ត៌មានទេសចរណ៍ក្នុងទីក្រុងគ្រប់គ្រាន់ឬទេ? | មាន (តិចបំផុតមានមួយនៅតាមទីកន្លែងទេសចរណ៍សំខាន់ៗដើម្បីទទួលបាន១ពិន្ទុ)<br>មិនមាន | ☐<br>☐ |
| | | តើកន្លែងទាក់ទាញទេសចរណ៍ក្នុងទីក្រុងត្រូវបានដាក់ស្លាកសញ្ញាសមរម្យឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានស្លាកសញ្ញាជាភាសារអង់គ្លេសផងដែរ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានផែនទីទេសចរណ៍សម្រាប់ទីក្រុង? | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានផែនទី និងព័ត៌មានទេសចរណ៍នានាដែលបានដាក់ចែកចាយនៅកន្លែងទេសចរប្រមូលផ្តុំគ្នា ឬទេ? | មាន<br>មិនមាន | |
| ៣ | ទីតាំងនៃមជ្ឈមណ្ឌលលក់ឥវ៉ាន់ និងហាងលក់រាយ | តើមានមជ្ឈមណ្ឌលលក់ឥវ៉ាន់ និងហាងលក់ឥវ៉ាន់ក្នុងចម្ងាយសមរម្យពីកន្លែងទេសចរប្រមូលផ្តុំគ្នាឬទេ?(កន្លែងទាក់ទាញទេសចរណ៍, សណ្ឋាគារ..) | មាន<br>មិនមាន | ☐<br>☐ |
| | | តើមានមជ្ឈមណ្ឌលសិប្បកម្មនៅជិតតំបន់ទេសចរណ៍ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើវត្ថុសិប្បកម្មដែលដាក់លក់មានគុណភាពល្អ និងជាវត្ថុតំណាងឲ្យទីក្រុងឬទេ? | មាន<br>មិនមាន | ☐<br>☐ |

| | | | | |
|---|---|---|---|---|
| | | តើផលិតផលតំបន់បានដាក់លក់ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| **៤** | **តំបន់សម្រាកលំហែ (តំបន់ទេសចរណ៍ ឧទ្យានសាធារណៈ កីឡា និងការកំសាន្ត** | តើកន្លែងកំសាន្តក្នុងទីក្រុងត្រូវបានចង្អុលបង្ហាញច្បាស់លាស់ និងប្រើប្រាស់បានសម្រាប់ទេសចរ? | មាន<br>មិនមាន | ☐<br>☐ |
| | | តើប្រជាជនអាចទៅលេងកំសាន្តបានឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| **៥** | **កំរិតនៃការពេញចិត្តរបស់ភ្ញៀវទេសចរណ៍** | តើមានធ្វើការស្ទង់មតិជាប្រចាំ ឬទេដើម្បីវាស់ស្ទង់អំពីកម្រិតនៃការពេញចិត្តរបស់ទេសចរលើភាពស្អាត ការស្វាគមន៍ និងបដិសណ្ឋាកិច្ច សន្តិសុខ និងការឲ្យតម្លៃអំពីការតុបតែង និងបរិស្ថាននៃទីក្រុង? | មាន<br>មិនមាន | ☐<br>☐ |
| | | តើទេសចរប៉ុន្មានភាគរយមានការពេញចិត្ត? | ____ (តិចបំផុត៧០%មានការពេញចិត្តដើម្បីទទួលបាន១ពិន្ទុ) | |
| | | តើបានធ្វើការស្ទង់មតិញឹកញាប់កម្រិតណា? | មួយឆ្នាំម្តង ឬច្រើនជាង (តិចបំផុតរៀងរាល់ឆ្នាំដើម្បីទទួលបាន១ពិន្ទុ)តិចជាង១ដងក្នុង១ឆ្នាំ | ☐ |
| | | តើលទ្ធផលពីការស្ទង់មតិបានដាក់ចេញជាសកម្មភាពដើម្បីពង្រឹងស្ថានភាពឲ្យកាន់តែប្រសើរឡើង ឬទេ? | មាន<br>មិនមាន | ☐<br>☐ |
| **-ចំនួននៃសូចនករលំអិតៈ៥<br>-ចំនួនលក្ខណៈវិនិច្ឆ័យៈ១៨** | | | **សរុប** | **១៨** |

## ៧ ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ានៈ ឡាប៊ិល

### ៧.១. ឡាប៊ិល

ASEAN Clean Tourist City Standard

❖ អត្ថន័យនៃរូបសញ្ញាឡាប៊ិលស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន

1. ផ្កាដែលមានរាងដូចទៅនឹងផ្កាឈូក
   - រុក្ខជាតិមួយប្រភេទដែលជំរុញអោយភាពសប្បាយរីករាយយ៉ាងប្រណិត សន្តិភាពនិងភាពស្រស់ស្អាត
   - ការទទួលស្គាល់ជាពានរង្វាន់មួយ និងស្តង់ដានៃសេវាកម្មទេសចរណ៍អាស៊ាន
2. ស្រទាប់ផ្កាក្រសោបជុំវិញស្លាកសញ្ញាអាស៊ានតំណាងឲ្យភាពធន់របស់ប្រទេសជាសមាជិក
3. ស្រមោលផ្សេងគ្នានៃព៌ត៌បៃតងមានន័យបញ្ជាក់ពីកិច្ចគាំពារបរិស្ថាន កំណើនសេដ្ឋកិច្ច និងការកើនឡើងនៃផលិតកម្មក្នុងឧស្សាហកម្មទេសចរណ៍។

### ៧.២. ពានរង្វាន់

- ទីក្រុងអាស៊ានដែលទទួលបានយ៉ាងហោចណាស់ចាប់ពី **៦០%** នៃពិន្ទុសរុបនឹងទទួលបានរង្វាន់ស្លាកសញ្ញាឡាប៊ិលទីក្រុងទេសចរណ៍ស្អាតអាស៊ាន។
- ទីក្រុងដែលឈ្នះរង្វាន់នឹងទទួលបានវិញ្ញាបនបត្របញ្ជាក់ការកោតសរសើរ និងបន្ទះដែលមានបោះពុម្ពរូបស្លាកសញ្ញាឡាប៊ិលទីក្រុងស្អាតទេសចរណ៍អាស៊ានដែលមានសុពលភាព **០៣ ឆ្នាំ**។

### ៧.៣. នីតិវិធីនៃការផ្តល់វិញ្ញាបនបត្រ

នីតិវិធីនៃការផ្តល់វិញ្ញាបនបត្រ ឬការវាយតម្លៃទៅដល់ទីក្រុង នឹងធ្វើឡើងដោយប្រើប្រាស់យន្តការដូចខាងក្រោមៈ

**ក.** ការវាយតម្លៃទទួលស្គាល់ នឹងត្រូវអនុវត្តដោយ **ស្ថាប័នថ្នាក់ជាតិមួយ/គណៈកម្មការថ្នាក់ជាតិមួយ**ដែលត្រូវបានតែងតាំង និងទទួលស្គាល់ដោយស្ថាប័នជាតិទេសចរណ៍អាស៊ាន (NTOs) របស់ប្រទេសជាសជមាជិកអាស៊ាន

**ខ.** **ការវាយតម្លៃបឋមមុនដោយខ្លួនឯង** (Self-assessment) នឹងត្រូវធ្វើឡើងដោយទីក្រុងបេក្ខភាពដែលមានបំណងចង់បានឡាប៊ិល មុនពេលបំពេញឯកសារដាក់ជូនមក NTOs តាមរយៈប្រទេសជាសមាជិកនីមួយៗ

គ. បន្ទាប់ពីការពិនិត្យទៅលើឯកសាររបស់ទីក្រុងបេក្ខភាពបានច្បាស់លាស់ហើយ **ស្ថាប័នថ្នាក់ជាតិ/គណៈកម្មការថ្នាក់ជាតិ**នឹងធ្វើការចុះពិនិត្យ និងវាយតម្លៃនៅតាមទីតាំងជាក់ស្តែង ព្រមទាំងការរៀបចំជា**របាយការណ៍នៃការចុះវាយតម្លៃជាក់ស្តែងមួយ** (Audit Report) ដើម្បីដាក់ជូនទៅ NTOs

ឃ. នៅពេលដែលទីក្រុងណាមួយអាចបំពេញទៅតាមលក្ខណវិនិច្ឆ័យ និងលក្ខខណ្ឌតម្រូវនៃស្តង់ដាហើយ NTOs របស់ប្រទេសនីមួយៗនឹងធ្វើការរាយការណ៍ជូននៅក្នុងកិច្ចប្រជុំ ទៅដល់**ក្រុមការងារ** (working group) **ឬគណៈកម្មាធិការ** (committee) **គុណភាពផលិតផលទេសចរណ៍របស់អាស៊ាន** (QTWG) នៅកម្រិតអាស៊ាន

ង. សុពលភាពនៃការផ្តល់វិញ្ញាបនបត្រទទួលស្គាល់នេះគឺ **បី (០៣) ឆ្នាំ** និង

ច. ការជ្រើសរើសទីក្រុងជាបេក្ខភាពនឹងត្រូវធ្វើឡើងដោយប្រទេសជាសមាជិកដោយឈរលើមូលដ្ឋាន**ស្ម័គ្រចិត្ត**មួយ និងការពិនិត្យមើលលើលក្ខណៈសម្បត្តិរបស់ទីក្រុងដែលអាចចូលរួមបាន។ វានឹង**មិនមានការកំណត់ពីចំនួនទីក្រុងជាជ័យលាភី** ដែលទទួលបានពានរង្វាន់នោះទេ និងក៏**មិនមានការបែងចែកពីប្រភេទនៃជ័យលាភី**នោះដែរ។